ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៣ សហវ

ថ្ងៃ ច័ន្ទ ៩រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

## ១-សេចក្តីផ្តើម

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃ ពុធ ៥ កើត ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃ ពុធ ៤ រោច ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ និងអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃ ពុធ ៤ រោច ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩។ ផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៦២២ សហវ.ប្រក ចុះថ្ងៃ សុក្រ ៦ រោច ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ និងប្រកាសលេខ ១៦២៣ សហវ.ប្រក ចុះថ្ងៃ សុក្រ ៦ រោច ខែ មិគសិរ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា បាន និងកំពុងបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្ររបស់ខ្លួនបន្តពីរាជរដ្ឋាភិបាលនីតិកាលទី ៥ ជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយ និងកាន់តែស្វាហាប់ក្នុងការបម្រើប្រជាជន ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍ និងជំរុញអនុវត្តការកែទម្រង់កាន់តែស៊ីជម្រៅ និងទូលំទូលាយលើគ្រប់វិស័យ ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង ស្របតាមឆន្ទៈ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន។

ដើម្បីគោលដៅនេះ, ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយឈរលើគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ចំនួន ៤ ដែលក្នុងនោះរួមមាន៖ (១)-ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ដោយទូលំទូលាយ

និងមានភាពប្រកួតប្រជែង ជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប, ការធានាស្ថិរភាពអត្រាប្តូរប្រាក់, ការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈដោយគត់មត់; (២)-បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាពជូនដល់ប្រជាជនកម្ពុជា ជាពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ជំនាញ, ព័ត៌មានទីផ្សារការងារ, ការកែលម្អលក្ខខណ្ឌការងារ, ការលើកកម្ពស់សកម្មភាពធុរកិច្ច និងការជំរុញការវិនិយោគ ទាំងក្នុងប្រទេស និងក្រៅប្រទេស; (៣)-សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% ការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ, ការអនុវត្តគោលនយោបាយគាំពារសង្គម, ការកាត់បន្ថយបន្ទុកជីវភាពរស់នៅ និងការផ្តល់សេវាសាធារណៈប្រកបដោយ-គុណភាព និងការកាត់បន្ថយគម្លាតសង្គម; និង (៤)-បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។

ក្នុងន័យនេះ ថវិកាឆ្នាំ ២០១៩ ត្រូវបានផ្តោតជាពិសេសលើ៖ (ទី១)-ការបន្តដំឡើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យកាន់តែល្អប្រសើរផង និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈផង; (ទី២)-ការវិនិយោគលើធនធានមនុស្ស និងការជំរុញអនុវត្តនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៧-២០២៥ របស់រាជរដ្ឋាភិបាល មានជាអាទិ៍ ការថែទាំសុខភាពមន្ត្រីសាធារណៈ, អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន, របបថែទាំសុខភាពសម្រាប់កម្មករ និងរបបឧបត្ថម្ភមាតុភាពសម្រាប់កម្មការិនី, របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ។ល។; (ទី៣)-ការកែទម្រង់សំដៅលើកកម្ពស់ និងកែលម្អប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈលើគ្រប់វិស័យ ដើម្បីឆ្លើយតបទៅនឹងសំណូមពរ និងសេចក្តីត្រូវការរបស់ប្រជាជន; និង(ទី៤)-ការផ្តល់អាទិភាពលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្លូវថ្នល់អគ្គិសនី និងប្រព័ន្ធធារាសាស្ត្រស្រោចស្រព ព្រមទាំងការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ និងជំនន់ទឹកភ្លៀងក្នុង ឆ្នាំ ២០១៨ នេះ ដើម្បីបន្តជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចទាំងក្នុង រយៈពេលខ្លី មធ្យម និងវែង ក៏ដូចជា ដោះស្រាយតម្រូវការប្រចាំថ្ងៃរបស់ប្រជាជន។

ផ្អែកតាមគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រខាងលើ ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយបន្តប្រកាន់យកគោលការណ៍ជាបច្ចេកទេសសំខាន់ៗ ដូចខាងក្រោម៖

*១/-ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល:* ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ចំណូលថវិការដ្ឋសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរ ដោយមានការកើនឡើងក្នុងសន្ទុះយ៉ាងលឿន ជាពិសេសក្នុងនីតិកាលទី ៥។ ប៉ុន្តែកំណើនចំណូលឆ្នាំ ២០១៩ អាចនឹងប្រឈមនឹងការថមថយនៃល្បឿន ដោយសារម្យ៉ាងកំណើននៃចំណូលកន្លងមកនេះ បានទទួលផលជាសំខាន់ពីវិធានការរដ្ឋបាលផ្នែកសារពើពន្ធ និងម្យ៉ាងទៀតឥទ្ធិពលនៃ "សង្គ្រាមពាណិជ្ជកម្ម" ក៏បាននិងកំពុងកើតឡើងដែរ។ ដូចនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធ ចាំបាច់ត្រូវបន្តរក្សាចលនការនៃការខិតខំប្រឹងប្រែង ក្នុងការកៀរគរចំណូលថវិកាឱ្យអស់

លទ្ធភាព ជាពិសេសពង្រឹងមន្ត្រីមានសមត្ថកិច្ច ក៏ដូចជាអង្គភាពពាក់ព័ន្ធនឹងការប្រមូលចំណូលរបស់ខ្លួន មិនឱ្យធ្លាក់ដៃក្នុងការបំពេញភារកិច្ចឡើយ តែក៏ត្រូវប្រយ័ត្នប្រយែង និងពង្រឹងអភិបាលកិច្ច និងយុត្តិធម៌ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារផងដែរ។

*២/-ការកំណត់លំដាប់អាទិភាព:* តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ ជាពិសេសលើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន។

*៣/-ការយកចិត្តទុកដាក់លើមនុស្ស:* ទន្ទឹមនឹងបន្តបង្កើនប្រាក់បៀវត្សអប្បបរមា ជូនមន្ត្រីរាជការគ្រប់ប្រភេទ ព្រមទាំងរបបតាវកាលិកចាំបាច់ផ្សេងៗ និងការគាំពារសង្គមផ្សេងៗទៀត, ថវិកាឆ្នាំ ២០១៩ ផ្តល់អាទិភាពដល់ការកសាង និងពង្រឹងធនធានមនុស្ស និងផ្តល់ការយកចិត្តទុកដាក់ដល់ការឧបត្ថម្ភគាំទ្រចំពោះមនុស្សដែលត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារផ្ទាល់លើការផ្តល់សេវាសាធារណៈ។

*៤/-កំណត់តម្លៃជាក់ស្តែងនៃកម្មវិធី/សកម្មភាព:* បន្តគិតគូរឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ និងគុណភាពក្នុងការអនុវត្តកម្មវិធី/សកម្មភាព ក្នុងគោលដៅជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា។

*៥/-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត:* បង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពអនុវត្តការងារផ្ទាល់ដែលនៅក្រោមឱវាទក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល ឬនៅតាមមូលដ្ឋាន ជាពិសេស តាមសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព ទន្ទឹមនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការទទួលខុសត្រូវនៅនឹងកន្លែង។

*៦/-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា:* ផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័នដែលកៀរគរចំណូលបានដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់។

*៧/-ការរក្សាតុល្យភាព និងចីរភាពថវិកា:* ស្ថិតក្រោមសម្ពាធនៃតម្រូវការចំណាយដែលចេះតែកើនឡើងក្នុងសន្ទុះថេរ ជាពិសេសសម្ពាធនៃចំណាយបន្ទុកបុគ្គលិក ចំណាយចរន្តមិនមែនបន្ទុកបុគ្គលិកដែលកើតឡើងថ្មីៗ ព្រមទាំងចំណាយវិនិយោគដើម្បីជំរុញការអភិវឌ្ឍ ក៏ដូចជាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន, ការរៀបចំថវិកាឆ្នាំ២០១៩ ត្រូវបានគោរពទាំងស្រុងទៅនឹង**គោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា** (Fiscal Consolidation) ដើម្បីបង្កើនឡើងវិញនូវប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលដែលត្រូវបានដកមកប្រើប្រាស់ក្នុងឆ្នាំ២០១៨ ប្រមាណជិត១%នៃ ផ.ស.ស. ដើម្បីបន្តធានារក្សាបាននូវលំហថវិកាក្នុងទំហំមួយសមស្របសម្រាប់ត្រៀមទប់ទល់នឹងវិបត្តិ ក៏ដូចជាហានិភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ។

ដូចនេះ ក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ច ដែលត្រូវបានគ្រោងក្នុងរង្វង់ ៧,១ % ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដើម្បីសម្រេចបានតាមគោលដៅនៃអាទិភាពគោលនយោបាយដូចបានគូសបញ្ជាក់ខាងលើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ បានកំណត់ក្របខណ្ឌថវិកាឆ្នាំ ២០១៩ ដូចតទៅ៖

- ចំណាយសរុបនៃថវិការដ្ឋស្មើនឹង ២៤,៧២% នៃ ផ.ស.ស.,
- ចំណូលក្នុងប្រទេសថវិការដ្ឋត្រូវសម្រេចឱ្យបានស្មើនឹង ១៩,២៨% នៃ ផ.ស.ស.,
- អតិរេកចរន្តត្រូវរក្សាឱ្យបានក្នុងកម្រិតប្រមាណ ២,៨១% នៃ ផ.ស.ស.,

- ឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយឱ្យនៅត្រឹមកម្រិតប្រមាណ -៥,៤៤% នៃ ផ.ស.ស.។

ដូចនេះ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ សម្រេចបានតាមគោលដៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៩ ដូចខាងក្រោម៖

## ២-លក្ខខណ្ឌ និងវិធានការក្នុងការអនុវត្តចំណូល-ចំណាយថវិកាឆ្នាំ ២០១៩

### ២.១- ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល-ចំណាយ

ដើម្បីឱ្យការអនុវត្តថវិកាមានភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូន ជាពិសេសដើម្បីធានាការឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សម្រាប់រយៈពេលពេញមួយឆ្នាំ ដែលមានបែងចែកលម្អិតទៅតាមខែ និងទៅតាមគំរូដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្តែង (តាមប្រតិទិននៃផែនការសកម្មភាពការងារ និងផែនការលទ្ធកម្ម) និងក្នុងក្របខណ្ឌនៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩។ ក្រសួង-ស្ថាប័ន ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយ ដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា), ដោយឡែក មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់ ដើម្បីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបូកសរុបរួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) និងទៅក្រសួង-ស្ថាប័ន ដែលជាខ្សែបណ្តោយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយដែលស្នើឡើងដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យនិងវាយតម្លៃលើអាទិភាពនៃតម្រូវការ និងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ទៅតាមមាតិកាថវិកាសម្រាប់អនុវត្ត។

ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវ និងសុក្រឹត្យ ព្រមទាំងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះ គឺជាប្រការចាំបាច់បំផុត។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវអភិក្រមការងារដូចខាងក្រោម៖

#### ២.១.១-ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

- អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនូវរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសដែលកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និងខែទី ២ និងការប៉ាន់ស្មានការអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២០ នៃខែនាចុងត្រីមាសនីមួយៗ*។

• មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី ១ និង ខែទី ២ និង ការប៉ាន់ស្មានអនុវត្តខែទី ៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១៥ នៃខែ នាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុបរួចផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ២០ នៃខែ នាចុងត្រីមាសនីមួយៗ*។

• អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំប្រជុំពិភាក្សា, តាមការចាំបាច់, ជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ *នៅរៀងរាល់ថ្ងៃទី ២៥ នៃខែ នាចុងត្រីមាសនីមួយៗ*។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសកម្មវិធីចំណូល-ចំណាយសម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកា ក្នុងកម្រិតឥណទានអតិបរមាសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ដោយចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ និងគណៈអភិបាលរាជធានី-ខេត្ត។

## ២.១.២-ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

អាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងវង្ងង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយអគ្គនាយកដ្ឋានថវិកា, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, អគ្គនាយកដ្ឋានរតនាគារជាតិ និងរតនាគាររាជធានី-ខេត្ត ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និង ត្រូវពិនិត្យទូទាត់និងបើកជាសាច់ប្រាក់តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយ និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ។ ក្នុងករណីដែលអាណត្តិបើកប្រាក់លើសពីវង្ងង់នៃកម្មវិធីចំណាយប្រចាំត្រីមាស, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវធ្វើសំណើសុំបន្ថែមកម្មវិធីចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២.១.៣-ការតាមដានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស

• អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង-ស្ថាប័នទាំងអស់ ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែ មកអគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់*។

• អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបញ្ជូនមកឱ្យអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយនូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ, របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពនៃគណនីប្រចាំខែ ដើម្បីឱ្យអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយ តាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ, ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន និងវាយតម្លៃនូវសភាពការណ៍អនុវត្តធៀបនឹងខែមុន, ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែ, ត្រីមាសដូចគ្នានៃឆ្នាំមុន *ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់*។

## ២.២- ការអនុវត្តការប្រមូលចំណូលថវិកា

ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលក្នុងប្រទេសថវិកាថ្នាក់ជាតិឱ្យស្មើនឹង ១៨,០% នៃ ផ.ស.ស. គឺស្មើនឹង ១៩ ៧៨៦ ២៦០ លានរៀល ដែលមានកំណើន ១២,២ % ធៀបនឹងច្បាប់ឆ្នាំ ២០១៨។ តាមគោលដៅនេះ៖

ក-ចំណូលចរន្តថ្នាក់ជាតិ ត្រូវសម្រេចឱ្យបានចំនួន ១៩ ៥៩៣ ១១១ លានរៀល ត្រូវជា ១៧,៨៣% នៃ ផ.ស.ស. គឺមានកំណើន ១២,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ដែលក្នុងនោះ៖

- **ចំណូលសារពើពន្ធ** ត្រូវសម្រេចឱ្យបានចំនួន ១៦ ៨៧៩ ០០០ លានរៀល ត្រូវជា ១៥,៣៦% នៃ ផ.ស.ស. គឺមានកំណើន ១២,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ដែលក្នុងនេះ៖
  - ចំណូលគយនិងរដ្ឋាករ ត្រូវបានគ្រោងចំនួន ៩ ០៩៤ ០០០ លានរៀល ត្រូវជា ៨,២៨%នៃ ផ.ស.ស. គឺមានកំណើន ៩,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៨
  - ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៧ ៧៨៥ ០០០ លានរៀល ត្រូវជា ៧,០៨% នៃ ផ.ស.ស. គឺមានកំណើន ១៥,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ក្នុងពេលដែលនៅឆ្នាំ ២០១៩ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬបង្កើនអត្រាពន្ធនោះទេ។
- **ចំណូលមិនមែនសារពើពន្ធ** ត្រូវបានគ្រោងចំនួន ២ ៧១៤ ១១១ លានរៀល ត្រូវជា ២,៤៧% នៃ ផ.ស.ស. គឺមានកំណើន ១៣,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ក្នុងនោះ៖
  - ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀតថ្នាក់ជាតិត្រូវបានគ្រោងចំនួន ២ ៣៩១ ៩៥៥ លានរៀល មានកំណើន ១៣,០% ធៀបនឹងច្បាប់ឆ្នាំ២០១៨,
  - ចំណូលពាក់ព័ន្ធនឹងកាតព្វកិច្ចពីកាស៊ីណូ ឆ្នោត អាជ្ញាប័ណ្ណ ត្រូវបានគ្រោងចំនួន ២៦៩ ១៥៦ លានរៀល មានកំណើន១៩,៦៩%ធៀបនឹងច្បាប់ឆ្នាំ២០១៨។ ដោយឡែកកម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ ត្រូវបានគ្រោងចំនួន ៥៣ ០០០លានរៀល មានកំណើន២២,០% ធៀបនឹងច្បាប់ឆ្នាំ២០១៨។

**ខ-ចំណូលមូលធន** ត្រូវបានគ្រោងចំនួន ៥ ៧៦៦ ៩១៧លានរៀល ត្រូវជា ៥,២៥%%នៃ ផ.ស.ស. គឺមានកំណើន ១៥,៩%ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ដែលក្នុងនោះ៖

- **ចំណូលមូលធនក្នុងប្រទេស** ដែលជាចំណូលមានប្រភពពីការសងត្រឡប់មកវិញនូវប្រាក់ដើមពីសហគ្រាសសាធារណៈរបស់រដ្ឋ ត្រូវសម្រេចឱ្យបានចំនួន ១៩៣ ១៤៩លានរៀល ត្រូវជា ០,១៨% នៃផ.ស.ស. គឺមានកំណើន៧,២%ធៀបនឹងច្បាប់ឆ្នាំ ២០១៨។
- **ចំណូលមូលធនក្រៅប្រទេស** ត្រូវសម្រេចឱ្យបានចំនួន ៥ ៥៧៣ ៧៦៨ លានរៀល ត្រូវជា ៥,០៧% នៃ ផ.ស.ស. គឺមានកំណើន ១៦,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ក្នុងនោះ៖
  - មូលនិធិទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន ២៥០ ០០០ លានរៀល ត្រូវជា ០,២៣% នៃ ផ.ស.ស. គឺស្មើនឹងច្បាប់ឆ្នាំ ២០១៨
  - ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ ដែលមានប្រភពពីហិរញ្ញប្បទានឥតសំណងនិងពីការខ្ចី ត្រូវបានគ្រោងចំនួន ៥ ៣២៣ ៧៦៨ លានរៀល ត្រូវជា ៤,៨៤% នៃ ផ.ស.ស. គឺមានកំណើន ១៧,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ត្រូវរៀបចំអនុវត្ត និងតាមដានជាប្រចាំ នូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលម្អិតទៅតាមខែ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានកាតព្វកិច្ចប្រមូលចំណូលពន្ធ ដែលជាចំណូលថវិកាថ្នាក់ជាតិ ឱ្យបានជាមធ្យមចំនួនប្រមាណ **៦៤៨ ៧៥០ លានរៀល** ក្នុងមួយខែ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានកាតព្វកិច្ចប្រមូលចំណូលពន្ធ និងអាករ ដែលជាចំណូលថវិកាថ្នាក់ជាតិ ឱ្យបានជាមធ្យមចំនួនប្រមាណ **៧៥៧ ៨៣៣ លានរៀល** ក្នុងមួយខែ។ ដោយឡែក ចំពោះចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ ត្រូវប្រមូលឱ្យបានជាមធ្យមចំនួនប្រមាណ **២២៦ ១៧៥ លានរៀល** ក្នុងមួយខែ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងទៅតាមប្រភេទនិងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខា, ទីស្នាក់ការ ឬ/និងមន្ត្រីដែលមានកាតព្វកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត។

ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី-ខេត្ត ត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស ដោយបែងចែកលម្អិតតាមខែ ដោយផ្អែកលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ, កិច្ចសន្យាសម្បទាននានា, ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និងសង្វាក់នៃការប្រមូលចំណូលកន្លងមក ព្រមទាំងដាក់ចេញនូវផែនការសកម្មភាព និងវិធានការអនុវត្តលម្អិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ។ អង្គភាពប្រមូលចំណូលត្រូវតាមដាន និងជំរុញជាប្រចាំនូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និងរិះរកវិធានការឱ្យបានទាន់ពេលវេលាក្នុងករណីពិនិត្យឃើញថាការប្រមូលចំណូលសម្រេចបានលទ្ធផលទាបជាងកម្មវិធីកំណត់។

## ២.៣-វិធានការអនុវត្តការប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ

ក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬដំឡើងពន្ធបន្ថែមដល់ប្រជាជន និងធុរជន លើកលែងតែអាករពិសេសលើទំនិញប្រណិត ទំនិញប៉ះពាល់សុខភាព និង/ឬបរិស្ថាន និងការប៉ះប៉ូវការបាត់បង់ចំណូលពីអនុលោមភាពតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រាជរដ្ឋាភិបាលនឹងដាក់ចេញឱ្យបានឆាប់ និងជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពនូវ **"យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣"** ដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពនៃកំណើនចំណូល ដូចដែលធ្លាប់សម្រេចបាននៅក្នុងបណ្តាឆ្នាំកន្លងមកផង និងដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រមូលចំណូលផង ដោយក្នុងនោះ ការជំរុញការរៀបចំការកែទម្រង់ប្រព័ន្ធពន្ធដារជាកញ្ចប់គ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅ រួមទាំងការរៀបចំច្បាប់ស្តីពីសារពើពន្ធថ្មីផង ដោយឈរលើគោលការណ៍ការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលថវិកាជាតិ ការធានាបាននូវបរិយាកាសប្រកួតប្រជែង ដោយតម្លាភាព គណនេយ្យភាព ស្មើភាព និងយុត្តិធម៌ ការលើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគ ព្រមទាំងធានាបាននូវសមធម៌សង្គម នៅក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក។ ក៏ប៉ុន្តែនៅក្នុងរយៈពេលបន្ទាន់ និងចំពោះមុខនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ ដើម្បីសម្រេចឱ្យបានតាមគោលដៅដែលបានគ្រោងទុក តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និង ផ្នែកមិនមែនសារពើពន្ធ ដូចខាងក្រោម៖

២.៣.១-ផ្នែកចំណូលគយ និងរដ្ឋាករ ត្រូវបានដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

- **វិធានការរដ្ឋបាល និងបច្ចេកទេសគយ តាមរយៈ៖**
  - ការជំរុញការអភិវឌ្ឍន៍និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ទាំងសម្រាប់ការងារបំពេញបែបបទគយ និងការងារគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេសគយ,
  - ការពង្រឹងប្រសិទ្ធភាព និងជំរុញការអនុវត្តច្បាប់ដោយអនុវត្តយន្តការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ ទាំងនៅដើមទី កណ្តាលទី និងចុងទី ជាពិសេសលើមុខទំនិញមានវេទយិតលើចំណូល តាមគោលការណ៍គ្រប់គ្រងហានិភ័យ,
  - ការបន្តធ្វើបច្ចុប្បន្នភាពជាប្រចាំនូវប្រព័ន្ធទិន្នន័យគ្រប់គ្រងអាជីវកម្មដ្ឋាន និងសន្និធិទំនិញសំខាន់ៗ ដែលជាប្រភពចំណូលពន្ធ និងអាករ,
  - ការបន្តផ្លាស់ប្តូរព័ត៌មានហានិភ័យជាមួយស្ថាប័នពាក់ព័ន្ធ និងការចូលរួមពីក្រុមធុរជនល្អបំផុត តាមបទប្បញ្ញត្តិដែលមានជាធរមាន,
  - ការបន្តពង្រឹងការត្រួតពិនិត្យការបញ្ចេញទំនិញពីគយ ដោយយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពនៃការផ្ទៀងផ្ទាត់សង្គតិភាព និងអនុលោមភាពរវាងទំនិញជាក់ស្តែង និងឯកសារនាំចេញ/នាំចូលដែលបានប្រកាស
  - ការរៀបចំឱ្យមានការបញ្ជូនទិន្នន័យឯកសារដឹកជញ្ជូន និងព័ត៌មានផ្សេងទៀតមកគយដោយស្វ័យប្រវត្តិ តាមរយៈការតភ្ជាប់ទៅវិញទៅមករវាងប្រព័ន្ធរបស់សហគមន៍កំពង់ផែ និងប្រព័ន្ធរបស់គយ
  - ការបន្តពង្រឹងប្រសិទ្ធភាពការងារបច្ចេកទេសគយរួមមាន៖ ការកំណត់តម្លៃគិតពន្ធគយ ការបញ្ជាក់លេខកូដទំនិញ និងវិញ្ញាបនបត្រប្រភពដើមទំនិញ
  - ការបន្តពង្រឹងការគោរពប្រតិបត្តិក្រមសីលធម៌របស់មន្ត្រីគយ និងពង្រឹងសមត្ថភាពមន្ត្រីគយ តាមរយៈវគ្គវិក្រឹត្យការ វគ្គបណ្តុះបណ្តាល និងវគ្គសិក្ខាសាលាផ្សេងៗ
- **វិធានការគោលនយោបាលពន្ធ និងអាករ តាមរយៈ៖**
  - វិធានការគោលនយោបាយពន្ធ និងអាករមួយចំនួន នឹងត្រូវដាក់ចេញដើម្បីប៉ះប៉ូវការបាត់បង់ចំណូលផ្នែកនេះដោយឈរលើមូលដ្ឋាននៃការសិក្សាចំណូលពន្ធគយដែលបាត់បង់ដោយការអនុវត្តកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត ព្រមទាំងសិក្សាវាយតម្លៃពីទំហំនិងវិសាលភាពនៃផលិតកម្ម ទំនិញក្នុងស្រុកដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារជំនួសការនាំចូល
  - ធ្វើវិចារណកម្មតារាងពន្ធគយកម្ពុជា ដើម្បីឱ្យអត្រាពន្ធ និងអាករកាន់តែមានសង្គតិភាពជាមួយគោលនយោបាយសារពើពន្ធ, គោលនយោបាយទាក់ទាញវិនិយោគពីបរទេស, គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម និងគោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យមរបស់រាជរដ្ឋាភិបាល
- **វិធានការកិច្ចសម្រួលពាណិជ្ជកម្ម និងកសាងវប្បធម៌អនុលោមភាព តាមរយៈ៖**
  - ការបន្តកែលម្អប្រសិទ្ធភាពប្រព័ន្ធស្វ័យប្រវត្តិកម្មគយអាស៊ីគូដា និង E-Customs ព្រមទាំងជំរុញការអភិវឌ្ឍនិងអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ

- ការពិនិត្យលទ្ធភាពពង្រីកការធ្វើវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ការបញ្ជាក់លេខកូដទំនិញ និងវិញ្ញាបនបត្រប្រភពដើមទំនិញទៅការិយាល័យគយបំពេញបែបបទនៅតាមមាត់ច្រក ដោយឈរលើមូលដ្ឋានកំណត់ត្រាអនុលោមភាពរបស់ក្រុមហ៊ុន និងតាមគោលការណ៍គ្រប់គ្រងហានិភ័យ
- ការអនុវត្តការសិក្សាអំពីពេលវេលាបញ្ចេញទំនិញ (Time Release Study -TRS) ហើយឈរលើលទ្ធផលនៃការសិក្សានេះ នឹងពិនិត្យឡើងវិញនូវនីតិវិធី និងបែបបទបញ្ចេញទំនិញពីគយ សំដៅកាត់បន្ថយឯកសារ ពេលវេលា ព្រមទាំងធ្វើឱ្យកាន់តែសាមញ្ញថែមទៀតនូវនីតិវិធីគយ ដោយឈរលើគោលការណ៍អនុលោមភាពខ្ពស់, ព្រមទាំងបន្តពង្រីកការលើកទឹកចិត្តក្រោមកម្មវិធី "ធុរជនល្អ" និងឈានទៅអនុវត្តសាកល្បង នូវយន្តការប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (Authorized Economic Operator-AEO) ស្របតាមស្តង់ដារគោលរបស់អង្គការគយពិភពលោក (WCO)
- ការបន្តពង្រឹងយន្តការភាពជាដៃគូជាមួយវិស័យឯកជនក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហា ឬកង្វល់នានារបស់ធុរជន
- ការរៀបចំនិងដាក់ឱ្យអនុវត្តក្រមសីលធម៌មជើងសារគយ សំដៅពង្រឹងវិន័យ, ការទទួលខុសត្រូវ និង អនុលោមភាពក្នុងការប្រកាសគយ
- ការរៀបចំ និងផ្សព្វផ្សាយឯកសារអប់រំលើកកម្ពស់ការយល់ដឹងដល់អាជីវករ និងសាធារណៈជនអំពីកាតព្វកិច្ចពន្ធ និងបច្ច័យអវិជ្ជមានផ្សេងៗពីការគេចវេះនិងបន្លំពន្ធនិងការប្រើប្រាស់ទំនិញគ្មានពន្ធ។

<u>២.៣.២-ផ្នែកចំណូលពន្ធដារ</u> ត្រូវបានដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

**ក. វិធានការគោលនយោបាយ**

- ការជំរុញការដាក់ឱ្យអនុវត្តពន្ធលើប្រាក់ចំណូលចំពោះប្រាក់ចំណេញមូលធន (Capital Gain Tax)
- ការដាក់ឱ្យអនុវត្តនូវគោលនយោបាយលើកទឹកចិត្តពន្ធចំពោះសហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព
- ការពិនិត្យ និងរៀបចំកែសម្រួលតម្លៃជាមូលដ្ឋានគិតពន្ធសម្រាប់ ពន្ធអចលនទ្រព្យ និងពន្ធ-ប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ
- ការសិក្សាអំពីការកែសម្រួលអត្រាអាករពិសេស និងវិធីសាស្ត្រក្នុងការកំណត់មូលដ្ឋានគិតអាករពិសេស
- ការសិក្សា និងរៀបចំបទប្បញ្ញត្តិស្តីពីការប្រមូលពន្ធលើប្រតិបត្តិការអេឡិកត្រូនិក (E-Commerce)
- ការពង្រីកបណ្តាញកិច្ចព្រមព្រៀងការយកពន្ធត្រួតគ្នាជាមួយបណ្តាប្រទេសអាស៊ាន និងប្រទេសដៃគូដទៃទៀត
- ការបន្តការកែទម្រង់គោលនយោបាយសារពើពន្ធដោយរួមទាំងបន្តរៀបចំសេចក្តីព្រាងវិសោធន-កម្មច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដទៃទៀត ដូចជា ធ្វើបច្ចុប្បន្នភាពពន្ធលើប្រាក់ចំណូល និងការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តពន្ធលើចំណូលបុគ្គល

- ការបញ្ឈប់ការលើកលែងពន្ធគ្រប់ប្រភេទដែលមិនមានចែងក្នុងបទប្បញ្ញត្តិស្ដីពីសារពើពន្ធ ។

## ខ. វិធានការរដ្ឋបាលសារពើពន្ធ

### ខ.១-ការចុះបញ្ជីអ្នកជាប់ពន្ធ៖

- ការបន្តគ្រប់គ្រងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធប្រមូលផ្តុំទិន្នន័យដោយស្វ័យប្រវត្តិ នៅថ្នាក់កណ្តាល,
- ការបន្តពង្រីកសេវាថតរូប និងស្កេនស្រាមដៃអ្នកជាប់ពន្ធទៅតាមបណ្តាសាខាពន្ធដារខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីសម្រួលដល់ការចុះបញ្ជីពន្ធដារ,
- ការបន្តធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធ និងកៀរចេញពីបញ្ជីចំពោះសហគ្រាស ដែលបាត់ខ្លួន និងមិនដាក់លិខិតប្រកាស,
- ការបន្តចុះត្រួតពិនិត្យដល់ទីតាំងរបស់ក្រុមហ៊ុនដែលស្នើសុំចុះបញ្ជីពន្ធដារ,
- ការជំរុញការចុះបញ្ជីពន្ធដារ ជាពិសេសតាមរយៈលទ្ធផលនៃការអង្កេតសហគ្រាសនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ,
- ការបន្តជំរុញការផ្ទេរសហគ្រាសទៅតាមកម្រិតផលរបររបស់អ្នកជាប់ពន្ធ តូច, មធ្យម,ធំ
- ការចុះផ្តល់សេវាពន្ធដារលើការចុះបញ្ជី និងធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យទាំងអស់នៅរាជធានីភ្នំពេញ និងនៅតំបន់ដែលជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យ
- ការបង្កើតយន្តការនៃការផ្តល់សេវាចុះបញ្ជីចលនទ្រព្យស្វ័យប្រវត្តិកម្មជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន
- ការរៀបចំយន្តការនៃការចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស តាមប្រព័ន្ធស្វ័យ-ប្រវត្តិកម្មជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ខ.២-ការផ្តល់សេវាអ្នកជាប់ពន្ធ

- ការកែសម្រួលយន្តការនៃការបង្វិលសងអាករលើតម្លៃបន្ថែម និងត្រៀមដាក់ឱ្យអនុវត្តការបង្វិលសងអាករលើតម្លៃបន្ថែមសម្រាប់ភ្ញៀវទេសចរណ៍
- ការបន្តរៀបចំបញ្ជីសំណួរចម្លើយដែលត្រូវបានសួរញឹកញាប់ និងចងក្រងដាក់ចូលក្នុងសៀវភៅណែនាំ និងដាក់ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ
- ការបន្តដោះស្រាយរាល់ចម្ងល់ និងបញ្ហារបស់អ្នកជាប់ពន្ធតាមរយៈ សេវាជជែកផ្ទាល់ជាមួយអគ្គនាយកដ្ឋានពន្ធដារ (GDT Live Chat), មជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរស័ព្ទ (Call Center), សារអេឡិកត្រូនិក (E-mail),បណ្តាញសង្គម (Facebook)
- ការធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរស័ព្ទ (Call Center) ដោយបន្ថែមមុខងារបញ្ជូនបន្ត (Call Transfer) ដើម្បីឆ្លើយតបទៅអ្នកជាប់ពន្ធប្រកបដោយវិជ្ជាជីវៈ និងទាន់ពេលវេលា
- បង្កើតវេទិកាផ្សាយផ្ទាល់ស្តីពីពន្ធដារ (Live Video)
- បង្កើតបញ្ជរពិគ្រោះយោបល់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ
- បង្កើនចំនួនមន្ត្រីទទួលបន្ទុកសេវាអ្នកជាប់ពន្ធ និងផ្តល់ធនធាន និងមធ្យោបាយបន្ថែមសម្រាប់ការងារផ្តល់សេវាអ្នកជាប់ពន្ធ

- បន្តផ្តល់សេវាជូនអ្នកជាប់ពន្ធ និងផ្សព្វផ្សាយដល់សាធារណជន តាមរយៈការរៀបចំសិក្ខាសាលា សារព័ត៌មាន វិទ្យុ ទូរទស្សន៍ គេហទំព័រ ផ្ទាំងផ្សព្វផ្សាយ ខិត្តប័ណ្ណផ្សព្វផ្សាយ និងសៀវភៅណែនាំ ដើម្បីបញ្ជ្រាប វប្បធម៌បង់ពន្ធ
- បន្តពង្រឹងសមត្ថភាពនិងកិច្ចសហការជាមួយភ្នាក់ងារពន្ធដារដូចជាគណនេយ្យករ សវនករជំនាញ អ្នកច្បាប់ និងភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីពង្រឹងការគោរពច្បាប់ និងស្វែងយល់ពីតម្រូវការរបស់អ្នកជាប់ពន្ធ
- ការពង្រឹងការពិនិត្យ និងដោះស្រាយរាល់បណ្តឹងតាមប្រអប់សំបុត្រនៅគ្រប់អង្គភាព
- ការបន្តបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវានូវស្តង់ដារសេវាសាធារណៈ ក្នុងនោះរួមមាន៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ។

**ខ.៣-ការដាក់លិខិតប្រកាសបង់ពន្ធ៖**

- រៀបចំបញ្ជរទទួលលិខិតប្រកាសពន្ធដោយស្វ័យប្រវត្តិ (Automatic Tax Return Kiosk)
- កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាសឱ្យបានខ្ពស់ជាអតិបរមាបន្ទាប់ពីបានកៀរចេញពីបញ្ជីពន្ធដារនូវសហគ្រាសដែលបាត់ខ្លួន និងមិនដាក់លិខិតប្រកាស ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- បន្តអនុវត្តវិធានការដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្ន ចំពោះអ្នកជាប់ពន្ធដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ខែជាប់គ្នា
- រៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (E-Filing) និងជំរុញការអនុវត្តបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (E-Payment) ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ
- បន្តពង្រឹង VAT cross-checking ។

**ខ.៤-ការធ្វើសវនកម្ម**

- ការបន្តកែលម្អវិធីសាស្ត្រកំណត់ហានិភ័យដោយស្វ័យប្រវត្តិ ការរៀបចំសារាចរណែនាំ និងជ្រើសរើស បន្ថែមមន្ត្រីសវនករ
- បន្តរៀបចំសៀវភៅណែនាំស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងសវនកម្ម ដើម្បីឱ្យអ្នកជាប់ពន្ធយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងពេលធ្វើសវនកម្ម
- ពង្រឹងមុខងារស៊ើបអង្កេតបទល្មើសពន្ធដារ ដើម្បីធ្វើការកំណត់អ្នកគេចវេះពន្ធឱ្យមានប្រសិទ្ធភាព
- បន្តជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ
- ពង្រឹងការទទួលព័ត៌មានអ្នកជាប់ពន្ធឱ្យមានលក្ខណៈស្វ័យប្រវត្តិពីអង្គភាពផ្ទៃក្នុង និងស្ថាប័នពាក់ព័ន្ធ
- ជំរុញការអនុវត្តប្រកាសស្តីពីវិធាន និងនីតិវិធីសម្រាប់បែងចែកចំណូល និងចំណាយក្នុងចំណោមបុគ្គលទាក់ទិន ។

ខ.៥-ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា៖

- កំណត់គោលដៅ និងអនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះអ្នកជំពាក់បំណុលពន្ធធំៗ
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- កំណត់បែងចែកបំណុលពន្ធដែលប្រមូលបាន និងមិនអាចប្រមូលបាន
- ពង្រឹងការគ្រប់គ្រងសហគ្រាសជំពាក់បំណុលពន្ធ ដែលបានស្នើសុំបង់ជាដំណាក់កាល ឱ្យមកទូទាត់តាមការសម្រេចរបស់អគ្គនាយកដ្ឋានពន្ធដារ
- ពង្រឹងការប្រមូលបំណុលពន្ធលើអចលនទ្រព្យនិងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- អនុវត្តគម្រោងគ្រប់គ្រង និងប្រមូលបំណុលពន្ធតាមរយៈការប្រមូលឯកសារ និងចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុន
- បន្តផ្តល់ការអប់រំដល់អ្នកជាប់ពន្ធស្តីពីនីតិវិធីដោះស្រាយបណ្តឹងតវ៉ា ។

ខ.៦-បច្ចេកវិទ្យាព័ត៌មាន៖ បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដោយអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់នូវការ៖

- រៀបចំបណ្តាញ Internet Gateway និង Payment Gateway រវាងអន្តរស្ថាប័ន ដើម្បីអាចបង្ការ និងទប់ទល់ហានិភ័យនៃការបាត់បង់ចំណូលពន្ធ ក៏ដូចជាធានានូវការគ្រប់គ្រងប្រមូលចំណូលពន្ធលើការធ្វើពាណិជ្ជកម្ម និងការទូទាត់នានាតាមប្រព័ន្ធអេឡិកត្រូនិក ( E-Commerce )
- កែលម្អ និងពង្រឹងការចុះបញ្ជីពន្ធដារឱ្យមានភាពងាយស្រួល និងសាមញ្ញ
  ១. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធចុះបញ្ជីសហគ្រាស
  ២. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធចុះបញ្ជីតាមអនឡាញ
  ៣. សិក្សា និងបង្កើតប្រព័ន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្តតាមអនឡាញ
  ៤. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីអចលនទ្រព្យ
- កែលម្អការដាក់លិខិតប្រកាស និងនីតិវិធីបង់ប្រាក់ ដើម្បីកាត់បន្ថយចំណាយនិងពេលវេលារបស់អ្នកជាប់ពន្ធ និងបន្ទុករបស់រដ្ឋបាលសារពើពន្ធ
  ១. ដាក់ឱ្យដំណើរការ និងបន្តអភិវឌ្ឍបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធ E-Filling
  ២. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងការបង់ពន្ធ Single Invoice
  ៣. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ ( E-Payment System ) និងអាចដំណើរការលើ Smart Devices បាន
- ពង្រីកការផ្សព្វផ្សាយចំណេះដឹង និងការអប់រំផ្នែកសារពើពន្ធ
  ១. រៀបចំ និងបង្កើតជា Video Clip Training ស្តីពីប្រភេទពន្ធផ្សេងៗ ដើម្បីផ្សព្វផ្សាយ និងបង្កើតការយល់ដឹងពីពន្ធ ជូនដល់សាធារណជន និងអ្នកជាប់ពន្ធ
  ២. រៀបចំ និងបង្កើតកម្មវិធីផ្សាយបន្តផ្ទាល់ ( Live Video and TV ) អំពីពន្ធដារ

៣. កែលម្អគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីងាយស្រួលដល់អ្នកជាប់ពន្ធស្វែងរកព័ត៌មានឱ្យបានឆាប់រហ័ស

- ផ្ដល់នូវជំនួយសំខាន់ៗតាមអនឡាញ សម្រាប់ដំណើរកិច្ចការងារដើម្បីធ្វើឱ្យរដ្ឋបាលសារពើពន្ធកាន់តែប្រសើរ

១. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារលើប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ( HR System )

២. សិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធ Call Center ទៅប្រព័ន្ធគ្រប់គ្រងព័ត៌មានក្រុមហ៊ុន ដើម្បីត្រួតពិនិត្យនិងគ្រប់គ្រងទិន្នន័យការ Call របស់ក្រុមហ៊ុននីមួយៗ

៣. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែប្រព័ន្ធគ្រប់គ្រងរបាយការណ៍ចំណូលពន្ធដារ ដើម្បីងាយស្រួល ក្នុងការតាមដាន ពិនិត្យ និងវិភាគលើចំណូល។

៤. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មី ដោយបន្ថែមមុខងារថ្មីៗ លើប្រព័ន្ធគ្រប់គ្រងសវនកម្ម ( Tax Audit System )

៥. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែដោយបន្ថែមមុខងារថ្មីៗលើប្រព័ន្ធគ្រប់គ្រងបំណុល ( Tax Arrears System )

៦. សិក្សា និងរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងការចៀសវាងយកពន្ធត្រួតគ្នា ( DTA System )

៧. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែទៅជំនាន់ថ្មីលើកម្មវិធីពិនិត្យនិងផ្ទៀងផ្ទាត់ប័ណ្ណប៉ាតង់ ( Patent Checking App )

៨. ធ្វើបច្ចុប្បន្នភាព និងកំណែប្រែដោយបន្ថែមមុខងារថ្មីៗ លើកម្មវិធី Mobile App សម្រាប់ចុះត្រួតពិនិត្យទីតាំងសហគ្រាស និងចុះទៅចែកប័ណ្ណប៉ាតង់ដល់ក្រុមហ៊ុន

៩. សិក្សា និងរៀបចំបង្កើតប្រព័ន្ធស្កេននិងផ្ញុំឯកសារលិខិតប្រកាសដោយស្វ័យប្រវត្តិ ( Batch Document Scanning System )

១០.សិក្សា និងរៀបចំបង្កើតប្រព័ន្ធបញ្ចូលទិន្នន័យដោយស្វ័យប្រវត្តិ ( Data Capturing Automate System )

១១.ធ្វើសន្ទានកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ ជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ។

**ខ.៧-វិធានការអភិបាលកិច្ច**

- លើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈ និងផ្លាស់ប្ដូរផ្នត់គំនិតមន្ត្រីពន្ធដារ ឱ្យទៅជាអ្នកផ្ដល់សេវាកាន់តែល្អប្រសើរជូនអ្នកជាប់ពន្ធ
- កែសម្រួលប្រព័ន្ធលើកទឹកចិត្តមន្ត្រីពន្ធដារ និងអនុវត្តវិធានការដាក់ទោសទណ្ឌចំពោះមន្ត្រីដែលប្រព្រឹត្តខុស

- ប្រកាន់យកអភិក្រមទាំង៤ប្រការគឺៈ (១)-អនុវត្តការងារប្រកបដោយវិជ្ជាជីវៈនិងគោរពក្រម-សីលធម៌វិជ្ជាជីវៈ (២)-អនុវត្តការងារជាក្រុម ៣)-អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និង (៤)-មិនត្រូវមើលរំលងកំហុសខ្លួនឯង
- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការចំណាយ ។

<u>២.៣.៣-ផ្នែកចំណូលមិនមែនសារពើពន្ធ</u> ត្រូវបានដាក់ចេញនូវវិធានការ ដូចខាងក្រោមៈ

- ការបង្កើនកិច្ចសហការជាមួយក្រសួង-ស្ថាប័នប្រមូលចំណូល ដើម្បីអនុវត្តអនុក្រឹត្យស្តីពីការគ្រប់-គ្រងចំណូលមិនមែនសារពើពន្ធ ដែលចូលជាធរមានកាលពីខែមិថុនាឆ្នាំ ២០១៨ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន ការទទួលខុសត្រូវច្បាស់លាស់ ការដាក់ទណ្ឌកម្ម សវនកម្ម និងអធិការកិច្ច ជាដើម
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលកំពុងដាក់ឱ្យអនុវត្តក្រសួង-ស្ថាប័នចំនួន ២៣ និងគ្រោងដាក់ឱ្យប្រើប្រាស់នៅតាមបណ្តារាជធានី-ខេត្តមួយចំនួនបន្ថែមទៀតនៅឆ្នាំ ២០១៩
- បន្តពង្រឹងការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធធនាគារ និងឱ្យទាន់ពេលវេលា
- បន្តពង្រឹងសមត្ថភាពមន្ត្រីក្នុងការចរចាកិច្ចសន្យាជាមួយភាគីឯកជន និងគ្រប់គ្រងចំណូល ជា-ពិសេស វិស័យរ៉ែ និងប្រេងកាត
- បន្តស្វែងរកមុខចំណូលថ្មីៗ និងពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលដែលមានស្រាប់ ជាពិសេស មុខចំណូលដែលមិនប៉ះពាល់ដល់កម្រិតជីវភាពរបស់ប្រជាជនទូទៅ។ ជាក់ស្តែង ចាប់ពីខែមេសា ឆ្នាំ ២០១៨ បានយកកម្រៃសេវាអ្នកដំណើរតាមផ្លូវអាកាស ដោយយកកម្រៃ ៥ ដុល្លារសម្រាប់អ្នកដំណើរអន្តរជាតិ និង ៣ ដុល្លារ សម្រាប់អ្នកដំណើរក្នុងស្រុក,
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការ-តឹងទារបំណុល ព្រមទាំងបន្តពង្រឹងការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវា សម្រាប់បង់ចំណូលឱ្យមានភាពងាយស្រួល និងតម្លាភាព
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកាស៊ីណូ និងល្បែងឆ្នោត ពិសេសតាមរយៈការជំរុញដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណ៍ និងល្បែងពាណិជ្ជកម្ម
- បន្តពង្រឹងការគ្រប់គ្រងកិច្ចសន្យាជួលកោះ និងឆ្នេរ ដោយតាមដានយ៉ាងម៉ឺងម៉ាត់ការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុន ការបង់ចំណូលចូលរដ្ឋ និងអនុវត្តយន្តការតឹងទារបំណុល ពិន័យ លុបចោលកិច្ចសន្យា ឬដកហូត យកប្រាក់កក់ ក្នុងករណីក្រុមហ៊ុនមិនបំពេញតាម
- បន្តពង្រឹងការប្រមូលចំណូលពីឈ្នួលដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើទំហំដីអនុញ្ញាតឱ្យឈូសឆាយ
- ពិនិត្យឡើងវិញនូវកិច្ចសន្យាជួលអគារ និងអចលនទ្រព្យ ដោយផ្អែកលើគោលការណ៍ទីផ្សារ និងភាពស្រុះស្រួលគ្នា ជាមួយភាគីជួល
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ។

## ២.៤- ការអនុវត្តចំណាយថវិកា

រាជរដ្ឋាភិបាលនឹងត្រូវការចំណាយថវិកាសរុបចំនួន ២៧ ១៦៤ ៩៩៦ លានរៀល ត្រូវជា ២៤,៧២% នៃ ផ.ស.ស. មានកំណើន ១១,៤% គឺកើនឡើង ០,១៨ ពិន្ទុភាគរយនៃ ផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុ ឆ្នាំ ២០១៨។ **ចំណាយចរន្តថវិកាថ្នាក់ជាតិ** មានចំនួន ១៦ ៨២៧ ២៨០លានរៀល ត្រូវជា ១៥,៣១% នៃ ផ.ស.ស. គឺមានកំណើន ១០,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។ **ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោង ៨ ៩៣៧ ៧៤៨ លានរៀល មានសមាមាត្រស្មើនឹង ៣៤,៧% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ៨,១៣% នៃ ផ.ស.ស. មានកំណើន ៨,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨។

ទន្ទឹមនេះ ដើម្បីធានាបានថា ថវិកាឆ្នាំ ២០១៩ ពិតជានឹងដើរតួនាទីជាឧបករណ៍ប្រកបដោយប្រសិទ្ធភាព ពិតប្រាកដសម្រាប់អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល, ការគ្រប់គ្រងនូវការអនុវត្ត ថវិកាត្រូវតែហ្មត់ចត់ និងម៉ឺងម៉ាត់ ទាំងក្នុងការគ្រប់គ្រង, ការប្រមូលចំណូល និងក្នុងការអនុវត្តចំណាយ ដោយ ត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ ថ្នាក់ក្រោមជាតិ, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុដទៃទៀត ជាពិសេសការអនុវត្តចំណាយ ត្រូវមានប្រសិទ្ធភាព ចំទិសដៅអាទិភាពពិតប្រាកដ មានភាពសន្សំសំចៃខ្ពស់ និងស្ថិតក្នុងរង្វង់នៃលទ្ធភាព ឥណទានថវិកាដែលមាន។ ទន្ទឹមគ្នានេះដែរ ត្រូវជំរុញអនុវត្តឱ្យបានជោគជ័យនូវបណ្តាផែនការសកម្មភាព និង វិធានការកែលម្អការគ្រប់គ្រងថវិកា និងបន្តដាក់ចេញនូវផែនការសកម្មភាព និងវិធានការថ្មីៗទៀត ក្នុង ក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "ដំណាក់កាលទី ៣ ឆ្នាំ ២០១៦-២០២០" និង យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមគូសរំលេចនូវបណ្តានីតិវិធី និង វិធានការអនុវត្ត ដូចខាងក្រោម៖

### ២.៤.១- ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម

ការស្នើសុំ និងការផ្តល់ធានាចំណាយ ត្រូវអនុវត្តតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤)**៖ ចំពោះចំណាយដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខណ្ឌ និង កាំប្រាក់ពីក្រសួងមុខងារសាធារណៈ ពុំតម្រូវឱ្យមានការសុំធានាចំណាយដាច់ដោយឡែកឡើយ ពោលគឺត្រូវ បោះផ្សាយអាណត្តិបើកប្រាក់តែម្តង ដោយឈរលើមូលដ្ឋានឥណទានដែលមាន។ ក្នុងន័យនេះ ដោយថាហេតុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចនឹងចាត់វិធានការបង្កកឥណទានចំណាយជំពូកផ្សេងទៀត ក្នុងករណី ពិនិត្យឃើញថា ឥណទានថវិកាបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័នមានមិនគ្រប់ចំនួន ស្របតាមការគណនា ដោយផ្អែកលើទិដ្ឋាការបញ្ជាក់ពីភាពត្រឹមត្រូវនៃចំនួនក្របខណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈ។ ដូច្នេះ ក្នុងពេលអនុវត្ត ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការគ្រប់គ្រង ឥណទានបន្ទុកបុគ្គលិកនេះឱ្យបានគ្រប់គ្រាន់ ដើម្បីចៀសវាងការរាំងស្ទះដល់ការបើកផ្តល់ប្រាក់បៀវត្ស។ ឥណទានថវិកាជំពូក ៦៤ នឹងមិនត្រូវបានអនុញ្ញាតឱ្យបន្ថែមឥណទានជូននោះទេ វៀរលែងតែក្នុងករណីមាន តម្រូវការបន្ថែមដោយសាររាជរដ្ឋាភិបាលមានការកែប្រែគោលនយោបាយ ឬផ្តល់គោលការណ៍ថ្មី ជាពិសេសក្នុង អំឡុងឆ្នាំអនុវត្ត ឬតែក្នុងករណីដែលតម្រូវការបន្ថែម ដោយសារមានការកើនឡើងនូវចំណូលថ្មីបន្ថែមពីលើ ផែនការប៉ុណ្ណោះ។ គោលការណ៍ថ្មីពាក់ព័ន្ធនឹងបៀវត្ស និងប្រាក់បំណាច់ផ្សេងៗ សម្រាប់ឆ្នាំ ២០១៩ ត្រូវអនុវត្ត

តាមអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ស្តីពីការកែប្រែ និងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព និងអនុក្រឹត្យស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ ព្រមទាំងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលផ្សេងទៀតសម្រាប់ការអនុវត្តថវិកាឆ្នាំ ២០១៩ ក្នុងនោះរួមមាន៖ ប្រាក់បំណាច់មុខងារសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីជាប់កិច្ចសន្យា និងការដំឡើងសោធននិវត្តជន។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវ៖

- ពង្រឹងការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់នូវចំនួនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាក្នុងគោលបំណងផ្ទៀងផ្ទាត់ធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីក្របខណ្ឌចូលថ្មី ដោយត្រូវគោរពឱ្យបានត្រឹមត្រូវតាមផែនការនៃការជ្រើសរើសមន្ត្រីចូលថ្មីសម្រាប់ឆ្នាំ ២០១៩

- ពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃការប្រើប្រាស់ប្រាក់រង្វាន់ពីកម្រៃសេវាសាធារណៈ ទាំងសម្រាប់ការលើកទឹកចិត្តដល់មន្ត្រីរាជការ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងសម្រាប់គាំទ្រដល់ការពង្រឹងយន្តការប្រមូលចំណូល។

- **ចំណាយក្រៅបន្ទុកបុគ្គលិក៖** រួមមាន ចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ចំណាយលើអគ្គិសនី ទឹក ទូរស័ព្ទ ទូរគមនាគមន៍ និងចំណាយឧបត្ថម្ភផ្សេងៗ ដូចជា៖ ប្រាក់បេសកកម្ម, បណ្តុះបណ្តាល, សិក្ខាសាលា ជាដើម ដែលមានគោលការណ៍កំណត់រួចហើយ ពុំតម្រូវឱ្យមានការសុំធានាចំណាយដោយឡែកទេ។ ចំពោះចំណាយប្រភេទនេះ អាណាប័កត្រូវប្រមូល និងរៀបចំលិខិតយុត្តិការចំណាយដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ឬ អាណត្តិនិយ័តកម្ម ស្នើសុំទូទាត់តែម្តង។ ទោះជាយ៉ាងនេះក្តី ប្រការនេះ ក៏មិនមានន័យថានឹងទទួលបានការទូទាត់ ឬការបើកផ្តល់ តាមសំណើជាស្វ័យប្រវត្តិនោះទេ។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវផ្តោត ការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំសំណើឱ្យទាន់ពេលវេលា ដោយ ភ្ជាប់មកជាមួយនូវឯកសារ និងលិខិតយុត្តិការត្រឹមត្រូវ និងគ្រប់គ្រាន់ ស្របតាមនីតិវិធីទូទាត់ ឬបើកផ្តល់។

ជារួម នីតិវិធីអនុវត្តចំណាយថវិកា ត្រូវផ្អែកលើក្របខណ្ឌគតិយុត្តដែលត្រូវបានដាក់ចេញ រួមមាន៖

- អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- អនុក្រឹត្យលេខ ២១៦ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ៥០៣ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ទិញចំណីសត្វ និងចំណីត្រីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសលេខ ១០២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- ប្រកាសលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់មុខងារនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨៨២ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់គម្រោងនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៧៣២ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការដាក់ឱ្យអនុវត្ត ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៥៤៩ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួល និងបំពេញបន្ថែមលេខកូដចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និង នីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- ប្រកាសអន្តរក្រសួងលេខ ៧២២ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពី គោលរបប និងនីតិវិធីចំណាយថវិកាសម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- សារាចរលេខ ០១២ សហវ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីគោលការណ៍ណែនាំ បន្ថែម សម្រាប់រយៈពេល, សោហ៊ុយធ្វើដំណើរ, តម្លៃសំបុត្រយន្តហោះ ចំពោះការបំពេញ បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- សារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីការបង្កើតតារាង ឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី
- សារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ ២០១៨ ស្តីពីកិច្ចបញ្ជិកា គណនេយ្យរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីកិច្ចបញ្ជិកា គណនេយ្យរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨៣៨ សហវ. ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីវិធាននិងនីតិវិធី ចំណាយសម្រាប់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលានៃក្រសួង-ស្ថាប័នថវិកាកម្មវិធី
- ប្រកាសលេខ ៨៣០ សហវ. ប្រក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីវិធាននិងនីតិវិធី នៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៨២៩ សហវ. ប្រក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួល ប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាល ថ្នាក់ជាតិ
- ប្រកាសអន្តរក្រសួងលេខ ៣៦៦ សហវ. ប្រក ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥ ស្តីពី នីតិវិធីនៃការអនុវត្តថវិកាសម្រាប់ដំណើរការសាលារៀនសាធារណៈ

- ប្រកាសលេខ ២៧៥ សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ១៥៨៧ សហវ. ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលប្រការ១៣ នៃប្រកាសលេខ ១៩៣៧ សហវ. ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ២៤២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- ប្រកាសលេខ ១៩៣៧ សហវ. ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- សារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការទូទាត់ត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីរាជការ
- ប្រកាសលេខ ១៥៨៩ សហវ. ប្រក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលតម្រូវឱ្យគ្រប់ភ្នាក់ងារប្រតិបត្តិគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមមាតិកាគណនីនៃប្លង់គណនេយ្យថវិកាថ្មី និងប្រភេទចំណាយក្នុងគម្រោង/កម្មវិធីហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍
- ប្រកាសអន្តរក្រសួងលេខ ៣០២ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល
- សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាវិនិយោគសាធារណៈ និងជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងអភិវឌ្ឍន៍មូលដ្ឋានអនុវត្តដោយអង្គភាពរដ្ឋ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត។

• **ចំណាយផ្សេងទៀត** ដែលត្រូវបានចាត់ទុកថាមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម ហើយដែលមិនស្ថិតក្នុងប្រភេទចំណាយដែលត្រូវបានគូសរំលេចខាងលើ ក្រសួង-ស្ថាប័នត្រូវស្នើសុំធានាចំណាយជាមុន ដោយត្រូវមានការពន្យល់ច្បាស់លាស់អំពីការចាំបាច់ អំពីគោលការណ៍អនុញ្ញាត ឬ/និង អំពីឯកសារគាំទ្រផ្សេងៗ។

២.៤.២-ចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ: តម្រូវឱ្យមានការសុំធានាចំណាយ ដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវគោរពឱ្យបាននូវគោលការណ៍សំខាន់ជាសារវន្ត ដូចខាងក្រោម៖

- មុខចំណាយត្រូវស្របតាមផែនការលទ្ធកម្ម។ ចំពោះចំណាយនេះ បើមិនមានបញ្ចូលក្នុងផែនការលទ្ធកម្មទេ មិនត្រូវបានអនុញ្ញាតឱ្យសុំ ឬផ្តល់ការធានាចំណាយឡើយ លើកលែងករណីមានចែងនៅក្នុងសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា។

-ការរៀបចំមុខចំណាយសម្រាប់ផែនការលទ្ធកម្ម ត្រូវស្របតាមស្មារតីនៃការចរចាថវិកា និងការព្រមព្រៀងគ្នានៅក្នុងពេលចរចាថវិកា។

- ចំពោះមុខចំណាយសម្រាប់ការជួសជុលក្នុងក្របខ័ណ្ឌចំណាយចរន្ត ក្រសួង-ស្ថាប័នត្រូវរួសរាន់លើកសំណើសុំធានាចំណាយនៅក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈ និង ធានាឱ្យការទូទាត់អាចអនុវត្តបានទាន់ពេលវេលា លើកលែងតែចំណាយជួសជុលហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលជាកម្មវត្ថុនៃការយោងបន្តទៅការិយបរិច្ឆេទឆ្នាំបន្ទាប់បាន។ ទោះជាយ៉ាងនេះក្តី ក្រសួង-ស្ថាប័នក៏ចាំបាច់ត្រូវត្រៀមថវិកាទុកសម្រាប់អនុវត្តការងារជួសជុលតូចតាច ដែលអាចកើតមានជាយថាហេតុ ជាពិសេស ការងារដែលមានទឹកប្រាក់ក្រោម ៤០ លានរៀល ឬមុខចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្ម តាមនីតិវិធីស្នង់តម្លៃដែលអាចសុំធានាចំណាយនៅក្នុងត្រីមាសទី ៣ នៃឆ្នាំបាន។ ដោយឡែក ចំពោះចំណាយសម្រាប់ការជួលសេវាកម្មលើការសិក្សាស្រាវជ្រាវ ឬពិសោធន៍ ក្រសួង-ស្ថាប័នក៏ត្រូវរួសរាន់លើកសំណើសុំធានាចំណាយនៅក្នុងត្រីមាសទី ១ ឬយ៉ាងយូរត្រឹមត្រីមាសទី ២ នៃឆ្នាំថវិកាផងដែរ ដើម្បីធានាភាពទាន់ពេលវេលានៃការបើកផ្តល់សាច់ប្រាក់ និងការទូទាត់បិទបញ្ជីចំណាយ។

- មុខចំណាយដែលស្នើសុំ ត្រូវមានឥណទានគ្រប់គ្រាន់សម្រាប់អនុវត្ត។ មិនអនុញ្ញាតជាដាច់ខាតចំពោះការចេញធានាចំណាយដោយគ្មានឥណទាន។ ក្នុងន័យនេះ ការស្នើសុំធានាចំណាយត្រូវគិតដល់៖

- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទាន និងចំណាយថវិកាបុរេ-ប្រទាន ដោយរាប់ទាំងចំណាយថវិកាបុរេប្រទានមុនឆ្នាំ ២០១៩ ប្រសិនបើមាន
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលបានធានារួច
- ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយ ដែលចាំបាច់ខានមិនបាន ដែលអាចកើតមាននាពេលខាងមុខ។

- ដើម្បីបង្កើនប្រសិទ្ធភាពចំណាយ និងធានាបាននូវភាពទាន់ពេលវេលានៃការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន ក៏ដូចជាអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ដោយផ្អែកលើភាពច្បាស់លាស់ និងត្រឹម-ត្រូវនៃសកម្មភាពរបស់កម្មវិធី និងភាពត្រឹមត្រូវនៃផែនការលទ្ធកម្ម ត្រូវបានអនុញ្ញាតឱ្យរៀបចំលើកសំណើសុំថវិកាចំណាយជាកញ្ចប់ប្រចាំឆមាស មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្តល់ទិដ្ឋាការធានាចំណាយ លើកលែងតែសកម្មភាពថ្មីមិនមាននៅក្នុងផែនការសកម្មភាពនៃថវិកាកម្មវិធី ដែលត្រូវជាកម្មវត្ថុនៃការពិភាក្សា និងផ្តល់ធានាចំណាយដោយឡែកជាករណីពិសេស។ រាល់សកម្មភាពដែលបានផ្តល់ធានាចំណាយរួចហើយ ប្រសិនបើក្រសួង-ស្ថាប័នមិនព្រមអនុវត្ត នោះគឺជាកម្មវត្ថុនៃការលុបធានាចំណាយវិញនៅឆមាសបន្ទាប់។

- ចំពោះមុខចំណាយធំៗ និងសំខាន់ៗ សម្រាប់បម្រើឱ្យសេចក្តីត្រូវការក្នុងការផ្តល់សេវាសាធារណៈ និងកិច្ចដំណើរការរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ហើយបែរជាមានការយឺតយ៉ាវ ឬមិនមានការរួសរាន់ស្នើសុំធានាចំណាយឱ្យបានទាន់មុនខែ មិថុនា ឆ្នាំ ២០១៩ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបង្អាក ឬកាត់ចេញតែម្តងនូវមុខចំណាយទាំងនោះ, ទោះបីមានក្នុងផែនការលទ្ធកម្មហើយក៏ដោយ, លើកលែងតែមុខចំណាយនោះមានភាពចំបាច់ និងមិនអាចពន្យារពេលបាន។

- គម្រោងចំណាយត្រូវមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយត្រូវមានបទដ្ឋានបច្ចេកទេស ឬយថាប្រភេទច្បាស់លាស់ដែលអាចជាមូលដ្ឋានសម្រាប់ការពិនិត្យអំពីភាពសមស្របនៃថ្លៃ, និងអំពីភាពចាំបាច់នៃគម្រោង ឬការងារ។ ក្នុងការលើកសំណើសុំធានាចំណាយ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តចាំបាច់ត្រូវគិតគូរឱ្យបានស្រេចបាច់អំពីតម្លៃស្របតាមទីផ្សារ អំពីបរិមាណ និងគុណភាពនៃទំនិញ និងសំណង់ដែលត្រូវធ្វើកិច្ចលទ្ធកម្មសាធារណៈ មុននឹងសុំធានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តល់ធានាចំណាយដោយផ្អែកលើភាពសមស្របនៃតម្លៃទីផ្សារធ្វើជាមូលដ្ឋាន។

- គម្រោងចំណាយមានភាពចាំបាច់ ដែលផ្តល់ផលប្រយោជន៍ពិតប្រាកដសម្រាប់ឱ្យក្រសួង-ស្ថាប័នសម្រេចបេសកកម្មការងាររបស់ខ្លួន ដោយចៀសវាងឱ្យបាននូវការបង្កើតចំណាយមិនចាំបាច់ និងខ្ជះខ្ជាយ។

- ការផ្តល់ធានាចំណាយ និងការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវតែមានការស្នើសុំជាលាយល័ក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិជាដាច់ខាត ដោយរាប់ទាំងចំណាយទាំងឡាយដែលមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុផងដែរ។

- ចំពោះចំណាយវិនិយោគ ការសុំនិងផ្តល់ធានាចំណាយត្រូវស្ថិតក្នុងរង្វង់ឥណទានថវិកាដែលបានអនុម័តមានលក្ខណៈកម្រិតកំណត់ ឬអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

- ឥណទានដែលបានកាត់/សន្សំពីធានាចំណាយ និងការអនុវត្តកិច្ចលទ្ធកម្ម នៃគម្រោងចំណាយរបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត នឹងត្រូវបង្កកមិនអនុញ្ញាតឱ្យចំណាយបន្ថែម ឬធ្វើនិយ័តកម្មសម្រាប់បម្រើឱ្យចំណាយផ្សេងទៀតឡើយ វៀរលែងតែមានការពន្យល់ច្បាស់លាស់ពីសេចក្តីត្រូវការចាំបាច់បំផុតប៉ុណ្ណោះ។

- មិនត្រូវសុំ និងផ្តល់ធានាចំណាយទៅលើការអនុវត្តនូវសកម្មភាពដែលនាំឱ្យមានការជ្រើសរើសមន្ត្រីថ្មី ឬមន្ត្រីជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្តដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។

- តម្លៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសឥណទានថវិកាដែលបានផ្តល់ការធានាចំណាយឡើយ។ ចំពោះករណីដែលការអនុវត្តនីតិវិធីលទ្ធកម្មលើសពីឥណទានដែលបានផ្តល់ពេលធានាចំណាយ ឬ ក៏មានតម្រូវការដូរបរិមាណ ទំហំការងារយថាប្រភេទ ក៏ដូចជាគុណភាព, តាមសំណើរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត, អគ្គនាយកដ្ឋានថវិកា/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម ឬក្រុមលទ្ធកម្មត្រូវ ពិភាក្សាគ្នាដើម្បីរិះរកវិធានការដោះស្រាយប្រកបដោយតម្លាភាព និងស្របតាមនីតិវិធីជាធរមាន។

នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវផ្អែកលើក្របខណ្ឌគតិយុត្តដែលបានដាក់ចេញ ដូចខាងក្រោម៖

- ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ



ԿՀ

- អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- អនុក្រឹត្យលេខ ១៣ អនក្រ. បក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- អនុក្រឹត្យលេខ ២១ អនក្រ. បក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- សារាចរណែនាំលេខ ០០១ សហវ.អលសា ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- សារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ
- សេចក្តីណែនាំលេខ ០០២ សហវ.អលសា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ស្តីពីវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ០៤៥សហវ.ប្រកចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តវិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈ
- ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ២៤៩ សហវ. ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- ប្រកាសលេខ ១៨៦៦ សហវ. ប្រក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការកំណត់ទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
- ប្រកាសអន្តរក្រសួងលេខ ៥៦៨ សហវ. ប្រក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ស្តីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ៣២៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់
- សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួន ដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា
- អនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- ប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា
- ប្រកាសលេខ ៩៨៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្តីពីក្រមសីលធម៌លទ្ធកម្ម

- ប្រកាសលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ស្ដីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្ដីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ
- ប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្ដីពីការរៀបចំផែនការលទ្ធកម្ម
- សេចក្ដីណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ស្ដីពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម។

- ដោយឡែក **ចំពោះការអនុវត្តចំណាយសម្រាប់ការទិញរថយន្ត** គឺត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម៖

- ដោយផ្អែកតាមលទ្ធផលនៃការចរចាថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបូកសរុបរួមនូវតម្រូវការទិញរថយន្តរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមានគ្រោងក្នុងឥណទានឆ្នាំ ២០១៩ និងទទួលបានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ។ ដូចនេះ ក្រសួង-ស្ថាប័ន មិនត្រូវបានអនុញ្ញាតឱ្យដាក់បញ្ចូលគម្រោងទិញរថយន្តផ្សេងទៀត ក្នុងផែនការលទ្ធកម្មឡើយ

- ផ្អែកតាមលទ្ធភាពឥណទានថវិកា និងតម្រូវការប្រើប្រាស់រថយន្តទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យក្រសួង-ស្ថាប័នលើកសំណើសុំទិញរថយន្តត្រឹមកម្រិតស្តង់ដារ (Standard Option) សម្រាប់ទាំងរថយន្ត Van និងទាំងរថយន្ត Pick-UP

- ក្រសួង-ស្ថាប័ន ត្រូវស្នើសុំគោលការណ៍ធានាចំណាយសម្រាប់ទិញរថយន្ត ដោយផ្អែកតាមចំនួនរថយន្តដែលទទួលបានគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល និងមានភ្ជាប់ជាមួយនូវបញ្ជីប៉ាន់តម្លៃលម្អិតសម្រាប់ទិញរថយន្ត (Quotation and Technical Specification) ជាផ្លូវការពីក្រុមហ៊ុនផ្គត់ផ្គង់រថយន្តដែលបានទទួលសិទ្ធិនាំចូលផ្ដាច់មុខ ដោយត្រូវគិតបញ្ចូលពន្ធ និងអាករផ្សេងៗគ្រប់ប្រភេទ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យផ្ដល់ធានាចំណាយ ព្រមជាមួយផ្ដល់ប្រាក់បុរេប្រទានជូនក្រសួង-ស្ថាប័នចំនួន ៥០% នៃទឹកប្រាក់ដែលផ្ដល់ធានាចំណាយសម្រាប់កក់នៅពេលចុះកិច្ចសន្យា។ ការទូទាត់បង្គ្រប់ត្រូវធ្វើឡើងបន្ទាប់ពីរថយន្តត្រូវបានប្រគល់ទទួល ត្រឹមត្រូវតាមកិច្ចសន្យា ហើយក្រសួង-ស្ថាប័នត្រូវបោះផ្សាយអាណត្តិនិយ័តកម្មស្មើទឹកប្រាក់ដែលបានបុរេប្រទាន និងអាណត្តិបើកប្រាក់ទូទាត់បង្គ្រប់ ដោយភ្ជាប់ជាមួយនូវឯកសារលិខិតយុត្តការគ្រប់គ្រាន់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។

- អនុញ្ញាតឱ្យអង្គភាពលទ្ធកម្មរបស់ក្រសួង-ស្ថាប័ន និងក្រុមលទ្ធកម្មនៃអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ, ដោយមិនមានកម្រិតទឹកប្រាក់, អនុវត្តវិធីសាស្ត្រចុះកិច្ចសន្យាផ្ទាល់ទិញរថយន្តជាមួយក្រុមហ៊ុនផ្គត់ផ្គង់រថយន្តណា ដែលបានទទួលសិទ្ធិនាំចូលផ្ដាច់មុខតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យចុះកិច្ចសន្យាផ្ទាល់ជាមួយក្រុមហ៊ុនកណ្ដាលឡើយ។ ក្រសួង-ស្ថាប័ន ត្រូវអនុវត្តនីតិវិធីបន្តឱ្យបានសមស្របតាមគោលការណ៍លទ្ធកម្មសាធារណៈជាធរមាន។

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងពិនិត្យដាក់បញ្ចូលបន្ថែមនូវការទិញមុខទំនិញមួយចំនួនផ្សេងទៀតដូចការទិញរថយន្តដែរ ដើម្បីពន្លឿននីតិវិធីចំណាយ និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការចំណាយថែមទៀត។

## ២.៤.៣- ការប្រគល់ទទួល (ទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា)

ការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា គឺជាដំណាក់កាលបន្ទាប់ពីក្រសួង-ស្ថាប័ន បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្ត និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ការប្រគល់ទទួល គឺពិនិត្យមើលពីភាពត្រឹមត្រូវទាំងមុខទំនិញ ឯកតា បរិមាណ តម្លៃ ប្រភព និងគុណភាព ព្រមទាំងផ្ទៀងផ្ទាត់មិនឱ្យលើសពីទឹកប្រាក់នៃការធានាចំណាយ និងមិនឱ្យខុសពីបទដ្ឋានបច្ចេកទេស និងយថាប្រភេទដែលបានធានាចំណាយ និងចុះកិច្ចសន្យាឡើយ។ ដូចនេះ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋ មិនត្រូវបានអនុញ្ញាតឱ្យទទួលយកទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាជាដាច់ខាត ប្រសិនបើមិនមានកិច្ចសន្យា ឬប្រសិនបើទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា មិនត្រូវបានអនុវត្តបានគ្រប់ចំនួន និងត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាទេ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រក្សាសិទ្ធិមិនទូទាត់ចំពោះករណីបែបនេះ ហើយក្រសួង-ស្ថាប័នដែលអនុវត្តខុសត្រូវទទួលខុសត្រូវលើភាពមិនប្រក្រតី។

## ២.៤.៤- ការបើកប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ

បន្តអនុវត្ត និងពង្រីកការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមប្រព័ន្ធធនាគារតាមការសម្រេចរបស់រាជរដ្ឋាភិបាល។ ហេតុនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំឯកសារសម្រាប់ការអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលា ដើម្បីធានាប្រសិទ្ធភាពនៃការបើកផ្តល់បៀវត្ស ឱ្យបានទៀងទាត់រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ។ ចំពោះក្រសួង ស្ថាប័នមួយចំនួនទៀត ដែលមិនទាន់អនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារបានពេញលេញនៅឡើយទេ ត្រូវពិនិត្យលទ្ធភាពក្នុងការពង្រីកការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារនេះនៅឆ្នាំ ២០១៩ នេះ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ។

ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត ឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់នូវសារាចរលេខ ០៧ សរ, ចុះថ្ងៃពុធ ៥ កើត ខែមិគសិរ ឆ្នាំ ច សំរឹទ្ធស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៨, ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត របស់រាជរដ្ឋាភិបាល។

ចំពោះចំនួនក្របខណ្ឌ និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យ និងអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញដោយក្រសួងមុខងារសាធារណៈ និងរាល់ក្របខ័ណ្ឌគតិយុត្តដែលនៅមានជាធរមាន ជាពិសេសអនុក្រឹត្យ សារាចរណែនាំ និងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ និង មន្ត្រីជាប់កិច្ចសន្យា, ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ, និងការកែសម្រួលប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការ ពីក្រសួង-ស្ថាប័នមួយ ទៅ

ក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង-ស្ថាប័ន ដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និងគ្រោងបៀវត្សនៅក្រសួង-ស្ថាប័នដែលបានផ្ទេរចូលឱ្យទាន់ពេលនៅឆ្នាំបន្ទាប់។

២.៤.៥-ការធ្វើចលនាឥណទានថវិកា

ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួនតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានលម្អិតនៅក្នុងសៀវភៅថវិកា។ ការធ្វើចលនាឥណទានថវិកា ត្រូវបានអនុញ្ញាតនៅដើមត្រីមាសទី ២ ក្រោយពីការអនុវត្តត្រីមាសមុនចប់សព្វគ្រប់។ ទោះ-យ៉ាងនេះក្តី ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់ តែចាំបាច់ត្រូវចំណាយ ការធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់ត្រូវមានការពន្យល់ឱ្យបានច្បាស់លាស់អំពីមូលហេតុ ជាពិសេសអំពីភាពចាំបាច់នៃការងារ និងអំពីភាពសល់ទំនេរនៃឥណទាន ដែលត្រូវផ្ទេរចេញបន្ទាប់ពីបណ្តាសកម្មភាពដែលត្រូវបានគ្រោង ត្រូវបានអនុវត្តរួច។ ប៉ុន្តែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគោរពឱ្យបាននូវមុខសញ្ញាឥណទានដែលសំខាន់សម្រាប់សកម្មភាពគន្លឹះ ដែលបម្រើឱ្យគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមី ក្នុងករណីពិនិត្យឃើញថាមិនបានគោរពនូវគោលការណ៍ខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមិនអនុញ្ញាតឱ្យមានការធ្វើចលនាឥណទានឡើយ។

ដូចនេះ រាល់សំណើសុំនិយ័តភាពត្រូវធ្វើស្របតាមគោលការណ៍ស្តីពីការធ្វើចលនាឥណទានថវិកា ដែលមានចែងក្នុង **គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី**។ ជាមួយគ្នានេះ *ក្រសួង-ស្ថាប័នថវិកាកម្មវិធី ទាំងរដ្ឋបាលកណ្តាល ទាំងមន្ទីរជំនាញរាជធានី-ខេត្ត ចាំបាច់ត្រូវកត់សម្គាល់ផងដែរថា គោលការណ៍ណែនាំនេះ មានចែងអំពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មនៃថវិកាកម្មវិធី ព្រមជាមួយនឹងការកំណត់នូវអនុគណនីចំណាយមួយចំនួន ដែលមិនត្រូវបានផ្តល់ប្រតិភូកម្មសិទ្ធិអំណាចក្នុងការផ្ទេរឥណទាន និងនិយ័តកម្មទេ រួមទាំងមុខចំណាយលើការប្រើប្រាស់អគ្គិសនី ទឹក សោហ៊ុយប្រេងឥន្ធនៈ និងទូរគមនាគមន៍ ហើយតម្រូវឱ្យស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេច។*

២.៤.៦- ករណីពិសេសដោយឡែកមួយចំនួន

ទន្ទឹមនឹងគោលការណ៍រួមខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីករណីដោយឡែកមួយចំនួនដូចខាងក្រោម៖

❖ ដោយត្រូវប្រកាន់ខ្ជាប់នូវស្មារតីនៃការសន្សំសំចៃខ្ពស់ មិនខ្ជះខ្ជាយថវិកាជាតិ ប្រសិទ្ធភាពការងារ និងតុល្យភាពទៅនឹងផលប្រយោជន៍ជាតិ ជាពិសេស ការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមទាញការយកចិត្តទុកដាក់ខ្ពស់ពីក្រសួង-ស្ថាប័នលើការរៀបចំពិធីបុណ្យ, សន្និបាត, សន្និសីទ, សិក្ខាសាលា, ពិព័រណ៍ និងកិច្ចប្រជុំថ្នាក់ជាតិគ្រប់ប្រភេទ និងថ្នាក់អន្តរជាតិកម្រិតអាស៊ាន តំបន់ និងពិភពលោក ដោយរៀបចំតែពិធី/ព្រឹត្តិការណ៍ដែលជាកាតព្វកិច្ចខានមិនបាន ឬផ្តល់ផលចំណេញដល់ប្រទេសជាតិជាចាំបាច់ប៉ុណ្ណោះ។ ដូច្នេះ ការរៀបចំពិធី/ព្រឹត្តិការណ៍នានា ប្រសិនបើមានការចាំបាច់ត្រូវធ្វើ គឺ៖

- ត្រូវឆ្លុះបញ្ចាំងពីភាពចាំបាច់ និងប្រសិទ្ធភាពនៃចំណាយនោះ,
- ត្រូវខិតខំចៀសវាងធ្វើនៅក្នុងអំឡុងពេលនៃតម្រូវការខ្ពស់ក្នុងវិស័យទេសចរណ៍ ឬរដូវ ទេសចរណ៍,

- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវចំណុច ៣.៧ នៃសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ១១៨៧ សជណ.សរ ចុះថ្ងៃសុក្រ ២ រោច ខែ អស្សុជ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី លើការរៀបចំពិធីជប់លៀង, ការទិញវត្ថុអនុស្សាវរីយ៍ និង ការទិញសម្ភារៈផ្សេងៗបម្រើក្នុងពិធី គឺត្រូវមានលក្ខណៈសន្សំសំចៃខ្ពស់បំផុត,
- ធានាការចូលរួមរបស់មន្ត្រី ក្នុងចំនួនចាំបាច់ និងតិចបំផុត ក្នុងការទ្រទ្រង់ដំណើរការរៀបចំ,
- ត្រូវរៀបចំនៅទីតាំង, ទីកន្លែង ឬតំបន់កៀកនឹងកន្លែងការងារ ដើម្បីសន្សំចំណាយថវិកា និងពេលវេលា, និង
- ត្រូវគ្រោងចំណាយត្រឹមតែក្នុងកញ្ចប់ឥណទាន ដែលបានវិភាជន៍ជូនប្រចាំឆ្នាំតែប៉ុណ្ណោះ ហើយមិនមែនជាកម្មវត្ថុនៃការស្នើសុំឥណទានបន្ថែមនោះទេ។

❖ លើសពីនេះ ការរៀបចំពិធីបុណ្យ, សន្និបាត, សន្និសីទ, សិក្ខាសាលា, ពិព័រណ៍ និងកិច្ចប្រជុំក្នុងប្រទេសថ្នាក់ជាតិគ្រប់ប្រភេទ និងថ្នាក់អន្តរជាតិកម្រិតអាស៊ាន តំបន់ និងពិភពលោក ចាំបាច់ត្រូវមានផែនការច្បាស់លាស់ និងត្រូវមានគ្រោងនៅក្នុងផែនការថវិកា ស្របតាមស្មារតីនៃការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងការសន្សំសំចៃខ្ពស់។ ជាមួយគ្នានេះ ត្រូវចៀសវាងអនុវត្តសកម្មភាពដោយមិនមានស្នើសុំគោលការណ៍ចំណាយជាមុនដែលនាំឱ្យមិនមានឥណទានគ្រប់គ្រាន់សម្រាប់ទូទាត់។ ក្នុងករណីមិនអនុលោមតាមគោលការណ៍កំណត់ខាងលើនេះទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ក្នុងការមិនពិនិត្យដោះស្រាយថវិកាជូនក្រសួង- ស្ថាប័ន ចំពោះសំណើពាក់ព័ន្ធនឹងការងារនេះឡើយ។ ការរៀបចំពិធី/ព្រឹត្តិការណ៍នានាជាលក្ខណៈអន្តរជាតិ រួមទាំងការទទួលភ្ញៀវអន្តរជាតិផង ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ស្មើទៅស្មើមក( Reciprocity ) ប៉ុន្តែ ត្រូវស្របតាមលទ្ធភាពនៃថវិការបស់ជាតិផងដែរ។

❖ កន្លងមកនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើនប្រាក់បេសកកម្មក្រៅប្រទេសជូនដល់មន្ត្រីរាជការ ដើម្បីធានាបាននូវការសន្សំសំចៃខ្ពស់បំផុត ដោយចៀសវាងឱ្យបាននូវការចំណាយលើបេសកកម្មក្រៅប្រទេស ដែលមិនចូលរួមចំណែកដល់ការសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំឱ្យគ្រប់ក្រសួង-ស្ថាប័នធ្វើអាទិភាវូបនីយកម្មបេសកកម្មក្រៅប្រទេសដោយពិនិត្យឡើងវិញអំពីភាពចាំបាច់/សារៈប្រយោជន៍ ឬ ផលប្រយោជន៍ដែលកម្ពុជាទទួលបានពីការចូលរួមនោះ ក្នុងការសម្រេចគោលដៅអាទិភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ចំនួនដងនៃបេសកកម្ម និងទំហំនៃគណៈ-ប្រតិភូឱ្យនៅចំនួនអប្បបរមា និងពាក់ព័ន្ធ ជាចំបាច់។ ក្រសួង-ស្ថាប័នត្រូវប្រកាន់ស្មារតីហ៊ានបដិសេធនូវការអញ្ជើញបេសកកម្មក្រៅប្រទេសទាំងឡាយណាដែលផ្តល់ប្រយោជន៍តិចតួច ឬ មិនសូវមានប្រយោជន៍ ឬ មិនមានប្រយោជន៍ដល់ក្រសួង-ស្ថាប័ន ហើយដែលយើងត្រូវចេញសោហ៊ុយខ្លួនឯង។ ក្រសួង-ស្ថាប័ន ត្រូវបំពេញបេសកកម្មក្រៅប្រទេសដោយផ្អែកជាចាំបាច់លើភាពទំនេរជាមុននៃឥណទានរបស់ក្រសួង-ស្ថាប័ន និងមិនមែនជាកម្មវត្ថុនៃការស្នើសុំឥណទានបន្ថែម ឬធ្វើចលនាឥណទាននោះទេ។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមគូសបញ្ជាក់ថា ចំណាយបេសកកម្មក្រៅប្រទេសត្រូវធ្វើឡើងតែនៅក្នុងឥណទានដែលបានវិភាជន៍ប្រចាំឆ្នាំ មានផែនការច្បាស់លាស់ជាមុន និងត្រូវមានប្រព័ន្ធរបាយការណ៍ដែលបង្ហាញពីសារៈប្រយោជន៍ និងវិភាគទាននៃបេសកកម្មទាំងនោះ ក្នុងការសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន។

❖ ដូចគ្នាដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើនប្រាក់បេសកកម្មក្នុងប្រទេសជូនដល់មន្ត្រីរាជការដើម្បីជានាភាពថ្លៃថ្នូរ និងការអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ថែមទៀត នៅក្នុងអំឡុងពេលបំពេញបេសកកម្ម តាមបណ្តារាជធានី ខេត្ត ទូទាំងប្រទេស។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និងអង្គភាពចំណាយពាក់ព័ន្ធទាំងអស់ត្រូវគោរព និងអនុវត្តប្រកបដោយតម្លាភាព នូវចំនួនថ្ងៃ និង ចំនួនមន្ត្រីចុះបេសកកម្មពិតប្រាកដ ត្រូវលុបបំបាត់ឱ្យបាននូវការបំប៉ោងចំនួនថ្ងៃ និង ចំនួនមន្ត្រីចុះបេសសកកម្ម លើសពីតម្រូវការជាក់ស្តែង ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវការរៀបចំកម្មវិធីនៅតាមរាជធានី ខេត្ត ដើម្បីគោលដៅទទួលបានប្រាក់បេសកកម្ម ឬ ក៏យកបេសកកម្មធ្វើជាត្រីមុខ។

## ២.៥-ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឆ្នាំ ២០១៩ គឺជាឆ្នាំទី ៤** នៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំណាក់កាលទី ២ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប្រព័ន្ធនេះ ត្រូវបានរៀបចំដោយអនុលោមទៅតាមស្តង់ដារឧត្តមានុវត្តន៍ ទាំងមូលដ្ឋានគណនេយ្យ និងប្រតិបត្តិការហិរញ្ញវត្ថុ។ នៅក្នុងដំណាក់កាលអនុវត្តថវិកាប្រតិបត្តិការចំណូល-ចំណាយថវិកាជាតិ រួមទាំងការទូទាត់ទាំងអស់ត្រូវធ្វើឡើងតាមប្រព័ន្ធ FMIS ដោយមានការកត់ត្រា, តាមដាន, និងគ្រប់គ្រងដោយស្វ័យប្រវត្តិ។ ដូចនេះ ដើម្បីឱ្យការទូទាត់ចំណូល-ចំណាយថវិកាជាតិអាចធ្វើទៅបាន ចាំបាច់ត្រូវមានឥណទានថវិកានៅក្នុងប្រព័ន្ធ ហើយទន្ទឹមនេះ រាល់ប្រតិបត្តិការចលនាឥណទានថវិកា(ទាំងការផ្ទេរ និងការបន្ថែមឥណទានថវិកា) ដែលធ្វើឡើងនៅគ្រប់អង្គភាព អនុវត្តថវិកាទាំងអស់ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ FMIS ។

ក្នុងគោលដៅខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការណែនាំដោយឡែកបន្ថែមទៀតអំពីនីតិវិធី និងតម្រូវការពាក់ព័ន្ធផ្សេងៗ ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការ និងកិច្ចសហការពីគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។

ផ្អែកលើលក្ខណៈសម្បត្តិដើម្បីអនុវត្តប្រព័ន្ធ FMIS, ក្រសួងចំនួន ១០ បន្ថែមទៀតត្រូវបានជ្រើសរើស និងចាប់ផ្តើមអនុវត្តពេញលេញនៅឆ្នាំ ២០១៩ រួមមាន៖ (១)-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, (២)-ក្រសួងសាធារណៈការ និងដឹកជញ្ជូន, (៣)-ក្រសួងអភិវឌ្ឍន៍ជនបទ, (៤)-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, (៥)-ក្រសួងទេសចរណ៍ (៦)-ក្រសួងពាណិជ្ជកម្ម, (៧)-ក្រសួងធនធានទឹក និងឧតុនិយម, (៨)- ក្រសួងព័ត៌មាន, (៩)-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង (១០)-ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា។

### ២.៥.១-ការអនុវត្តនៃអង្គភាពថវិកា និង មាតិកាថវិកាតាម FMIS

ប្រព័ន្ធ FMIS គឺជាឧបករណ៍គន្លឹះក្នុងការជំរុញការអនុវត្តថវិកាកម្មវិធីប្រកបដោយតម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព ដោយសារប្រព័ន្ធនេះត្រូវបានអនុវត្តដោយឈរលើមាតិកាថវិកាដែលមាន ៧ ចំណាត់ថ្នាក់ (១-សេដ្ឋកិច្ច, ២-រដ្ឋបាល, ៣-ភូមិសាស្ត្រ, ៤-កម្មវិធី, ៥-គម្រោង, ៦-មូលនិធិ, និង ៧-មុខងារ) ដែលនាំឱ្យការវិភាជថវិកាមានភាពច្បាស់លាស់ និងគ្រប់គ្រងតាមអង្គភាពថវិកាគ្រប់លំដាប់ថ្នាក់។ ការគ្រប់គ្រង និងតាមដាន ការអនុវត្តថវិកាតាមកម្មវិធីនីមួយៗរហូតដល់ចង្កោមសកម្មភាព អាចធ្វើបានយ៉ាងងាយស្រួលតាមរយៈការអនុវត្តប្រព័ន្ធ FMIS ដោយមានការផ្សារភ្ជាប់នឹងចំណាត់ថ្នាក់សេដ្ឋកិច្ច, មុខងារ, រដ្ឋបាល និងចំណាត់ថ្នាក់ផ្សេងៗទៀត។

២.៥.២.ការធ្វើវិសហមជ្ឈការឈានឆ្ពោះទៅវិមជ្ឈការថវិកាតាម FMIS

ការអនុវត្តវិមជ្ឈការគ្រប់គ្រង និងអនុវត្តថវិកា អាចធ្វើទៅបានលុះត្រាតែមានមូលដ្ឋាននៃការគ្រប់គ្រង និងតាមដានការអនុវត្តថវិកា ដែលធានាបាននូវគណនេយ្យភាពច្បាស់លាស់។ ដោយឡែកប្រព័ន្ធ FMIS គឺជាមធ្យោបាយដែលបានត្រូវទទួលស្គាល់ជាទូទៅថា ជាឧបករណ៍ដែលធានាដល់ការធ្វើវិមជ្ឈការនៃការអនុវត្តថវិកាដែលអាចគ្រប់គ្រងបាន ដោយហេតុថាប្រព័ន្ធនេះ អនុញ្ញាតឱ្យមានការអនុវត្ត និង គ្រប់គ្រងថវិកានៅតាមអង្គភាពអនុវត្តថវិកានានា តែប្រមូលផ្តុំព័ត៌មាននៃប្រតិបត្តិការទាំងនោះនៅក្នុងប្រព័ន្ធតែមួយ។

២.៥.៣.ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍តាម FMIS

ការអនុវត្តប្រព័ន្ធ FMIS នឹងជួយពន្លឿនការត្រួតពិនិត្យ តាមដានអនុវត្តថវិកាបានទាន់ពេលវេលា និងអាចធ្វើរបាយការណ៍តាមគ្រប់ទម្រង់ និងតម្រូវការសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ និងការវិភាគនានា។ តាមរយៈប្រព័ន្ធ FMIS ព័ត៌មាននៃការអនុវត្តថវិកាស្ថិតក្នុងប្រព័ន្ធតែមួយ និងផ្តល់នូវព័ត៌មានសុក្រឹត្យពីប្រភពតែមួយ។

តាមរយៈប្រព័ន្ធ FMIS អង្គភាពអនុវត្តថវិកានីមួយៗអាចតាមដានស្ថានភាពនៃការអនុវត្តថវិការបស់ខ្លួនបានគ្រប់ពេលវេលា រួមមាន ថវិកាតាមផែនការ, ចលនាឥណទាន, ឥណទានធានាចំណាយ, ឥណទានចំណាយថវិកាជាក់ស្តែង និងសមតុល្យថវិកា។ ដូច្នេះ កម្រិតតម្លាភាពនៃការអនុវត្តថវិកាកាន់តែអាចឆ្លុះបញ្ចាំងបាន ហើយអង្គភាពអនុវត្តថវិកានីមួយៗអាចធ្វើការវិភាគ, កែសម្រួលល្បឿននៃមុខចំណាយ ដើម្បីអនុវត្តឱ្យបានជាសមិទ្ធផលទៅតាមផែនការអនុម័តរួច និងមានឱកាសក្នុងការកែតម្រូវនៅពេលគ្រោង ផែនការថវិកាសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត ។

ការអនុវត្តថវិកាត្រូវបានធ្វើឡើង ដោយឈរនៅលើមូលដ្ឋាននៃការគ្រប់គ្រងសាច់ប្រាក់មួយច្បាស់លាស់ ដោយមានការធ្វើសមតុល្យថ្លឹងថ្លែងទៅលើចំណូលថវិកា និងចំណាយថវិកា។ ក្នុងពេលដែលគ្រប់អង្គភាពអនុវត្តថវិកាទាំងអស់ជឿជាក់ និង ចូលរួមក្នុងការអនុវត្តថវិកាតាមប្រព័ន្ធ FMIS នោះ ដំណើរការនៃការអនុវត្តថវិកានឹងប្រព្រឹត្តទៅបានដោយរលូន តាមរយៈការងាកមករកការទូទាត់ចំណាយថវិកាដោយត្រង់ ដោយពុំចាំបាច់ប្រើប្រាស់កញ្ចប់ថវិកាបុរេប្រទាន និងពង្រឹងការអនុវត្តថវិកាដោយឈរលើមូលដ្ឋាននៃថវិកាជាសាកល ព្រមទាំងអនុវត្តតាមគណនីរតនាគារទោលយ៉ាងពិតប្រាកដ ។

## ៣.ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍

គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវពង្រឹងតួនាទីរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង/នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ខ្លួន ជាមួយគ្នានឹងការពង្រឹងតួនាទីរបស់អគ្គាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គាធិការដ្ឋានក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការត្រួតពិនិត្យ ការអនុវត្តថវិកាជាតិជាពិសេសការត្រួតពិនិត្យជាក់ស្តែងរាល់ការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាជាតិ ដោយវាយតម្លៃនូវការទទួលខុសត្រូវ លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមបណ្តាក្រសួង-ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល។

ដើម្បីបង្កើនគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេសដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយផ្ញើ

មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ឱ្យបានទៀងទាត់ទៅតាមគំរូដែលបានផ្ញើជូន និងទៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

❖ របាយការណ៍ហិរញ្ញវត្ថុ

- របាយការណ៍ប្រចាំខែ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់ ។*
- របាយការណ៍ប្រចាំត្រីមាស *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែនៅដើមត្រីមាសបន្ទាប់ ។*
- របាយការណ៍ឆមាសទី ១ *ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមសប្តាហ៍ទី ២ នៃខែ កក្កដា ។*
- របាយការណ៍ប្រចាំឆ្នាំបឋម *ត្រូវផ្ញើយ៉ាងយឺតបំផុតត្រឹម ខែ មករា ឆ្នាំ ២០២០ មកអគ្គនាយកដ្ឋានថវិកា និងត្រូវផ្ញើរបាយការណ៍សម្រេចចុងក្រោយមកអគ្គនាយកដ្ឋានរតនាគារជាតិយ៉ាងយឺតបំផុតត្រឹមខែ មីនា ឆ្នាំ ២០២០។*

❖ របាយការណ៍សមិទ្ធកម្ម

ដើម្បីជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បូកសរុប និងតាមដានការអនុវត្តថវិកាកម្មវិធី និងធ្វើរបាយការណ៍បូកសរុបអំពីសមិទ្ធកម្ម, ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលអនុវត្តថវិកាកម្មវិធី ត្រូវរៀបចំទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម ទៅតាមគំរូ និងកាលបរិច្ឆេទ ដូចមានចែងក្នុង **គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី**។ ផ្អែកតាមប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ស្តីពី**សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា** របាយការណ៍សមិទ្ធកម្ម ត្រូវធ្វើឡើងតាមការិយបរិច្ឆេទថ្មីដូចខាងក្រោម៖

- ផ្តល់តារាងសូចនាករលទ្ធផលក្នុងឆ្នាំ ឬធាតុចេញ (Output) និងលទ្ធផលចុងក្រោយ (Outcome) ដែលគ្រោងនឹងសម្រេចឱ្យបាននៅឆ្នាំ ២០១៩ (តាមទម្រង់ដែលបានកំណត់) ស្របទៅតាមកញ្ចប់ថវិកាដែលបានវិភាជ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) *ឱ្យបានមុនដំណាច់ខែមករា ឆ្នាំ ២០១៩*
- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស (តាមទម្រង់ដែលមានភ្ជាប់) កម្រិតចង្កោមសកម្មភាព និង/ឬ កម្រិតអនុកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) *យ៉ាងយូរបំផុត ២០ ថ្ងៃ បន្ទាប់ពីបញ្ចប់ការអនុវត្តនៃឆមាសទី១*
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ (តាមទម្រង់ដែលមានភ្ជាប់) ពីកម្រិតចង្កោមសកម្មភាពដល់កម្រិតកម្មវិធី ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) *យ៉ាងយូរបំផុតត្រឹមខែ មីនា នៃឆ្នាំបន្ទាប់ គឺឆ្នាំ ២០២០* ។

ផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុអនុវត្តខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើអធិការកិច្ចហិរញ្ញវត្ថុជាក់ស្តែង តាមការចាំបាច់លើការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤. នីតិវិធីនៃការគ្រប់គ្រង និងអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

រាជរដ្ឋាភិបាល បានរៀបចំ និងដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងភាពឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ដូចនេះ

គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវគ្រប់គ្រង និងអនុវត្តថវិកា ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្ត ដែលបានដាក់ចេញរួមមាន៖

- ប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- អនុក្រឹត្យលេខ ១៣៩ អនក្រ. បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់គ្រឹស្ថានសាធារណៈរដ្ឋបាល
- ប្រកាសលេខ ០១៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹស្ថានសាធារណៈរដ្ឋបាល, និង
- លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ដែលនឹងត្រូវដាក់ឱ្យអនុវត្តសម្រាប់បម្រើកិច្ចដំណើរការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ៥. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវពង្រឹងតាមវិធានការដូចខាងក្រោម៖

- ជំរុញរៀបចំកម្មវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីដាក់ដើម្បីដាក់ឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋប្រើប្រាស់ក្នុងឆ្នាំ ២០១៩

- ក្រសួង-ស្ថាប័ន រាជធានី ខេត្ត ត្រូវជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវទទួលខុសត្រូវរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០១៧ ឱ្យបានតាមពេលកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចឱ្យបានតាមការកំណត់ក្នុងការរៀបចំតារាងប្រៀបធៀបកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ ២០១៧ នៅថ្នាក់ក្រោមជាតិ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិ ចូលក្នុងបញ្ជីសារពើភ័ណ្ឌ។

## ៦. វិធានការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា

នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុកដើម្បីរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នត្រូវមានវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និងរក្សាឱ្យបានស្ថិរភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅកម្ពុជា

- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងត្រៀមវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដោយចៀសវាងប៉ះពាល់ដល់សកម្មភាពអាទិភាពខ្ពស់ ក្នុងករណីមានការតម្រឹមចំណាយជាយថាហេតុ

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យ លើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់។

## ៧.វិធានការលើកកម្ពស់តម្លាភាពនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

ក្នុងការលើកកម្ពស់តម្លាភាពនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរៀបចំដាក់នៅក្នុងគេហទំព័រនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវឯកសារពាក់ព័ន្ធនឹងច្បាប់ថវិកាឆ្នាំ ២០១៩ រួមទាំងការរៀបចំឯកសារថវិកាសង្ខេប (Budget In Brief) ដើម្បីផ្តល់ជាព័ត៌មានដល់សាធារណៈជនទូទៅ ឱ្យបានយល់អំពីគោលដៅនៃការប្រើប្រាស់ថវិកាឆ្នាំ ២០១៩។ ទន្ទឹមនេះ ក្រសួង-ស្ថាប័ន ត្រូវផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ខ្លួនផងដែរនូវរចនាសម្ព័ន្ធគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន រួមមាន៖ គោលបំណងគោលនយោបាយ និងកម្មវិធីដែលក្រសួងបានដាក់អនុវត្ត និងការបែងចែកថវិកាទៅតាមរចនាសម្ព័ន្ធកម្មវិធី <u>តាមគំរូតារាងជូនភ្ជាប់</u>។

## ៨. ទណ្ឌកម្មនិងការទទួលខុសត្រូវចំពោះមន្ត្រីសាធារណៈ

មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវការអនុវត្ត អភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាពខ្ពស់ តាមវិធានការច្បាប់ និងលិខិតបទដ្ឋានជាធរមានដូចខាងក្រោម៖

- ចាត់វិធានការរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈណាដែលបានប្រព្រឹត្តនូវកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលទោសតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងទទួលតាមកម្រិតទោសទណ្ឌនៃក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិព្រហ្មទណ្ឌ,

- គ្រប់មន្ត្រីសាធារណៈ ត្រូវហ៊ានទទួលខុសត្រូវនូវកំហុសឆ្គងដែលបានប្រព្រឹត្ត និងកំពុងអនុវត្តប្រតិបត្តិការលើការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ ទៅតាមបទដ្ឋានគតិយុត្ត នៃវិន័យហិរញ្ញវត្ថុសាធារណៈ សារាចរ ប្រកាស អនុក្រឹត្យ ដែលបានណែនាំដោយរាជរដ្ឋាភិបាល,

- ចាត់វិធានការតាមវិន័យរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈដែលបានធ្វើឱ្យបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ ទោះតម្លៃនៃការបាត់បង់ ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬខូចខាតបានក្លាយជាបំណុលសាធារណៈក្តី មន្ត្រីសាធារណៈនោះត្រូវសង និងត្រូវបង់ជាប្រាក់កាសសាធារណៈចូលថវិការដ្ឋវិញ។

## ៩. សេចក្តីសន្និដ្ឋាន

ការរៀបចំថវិកាឆ្នាំ ២០១៩ ទោះបីជាជួបប្រទះនឹងបញ្ហាច្រើន រួមទាំងបញ្ហាប្រឈម និងហានិភ័យមួយ

ចំនួនយ៉ាងណាក្តី ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជសម្រាប់អនុវត្តអាទិភាពគោលនយោបាយសំខាន់ៗជាសារវន្ត ដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីបន្តសម្រេចបាននូវលទ្ធផលបន្ថែមទៀតជូនប្រជាជន ពិសេសនៅក្នុងឆ្នាំ ២០១៩ ដែលជាឆ្នាំចាប់ផ្តើមនៃនីតិកាលទី ៦ នៃរដ្ឋសភា។

សរុបមក ថវិកាឆ្នាំ២០១៩ គឺត្រូវបានរៀបចំឡើងតាមគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation) ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើមនុស្ស និងការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល ហើយអាចប្រសិទ្ធនាមបានថាជា **"ថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធផលដែលសម្រេចបានដោយលំបាក និងការបន្តបុកគ្រឹះថ្មីៗសម្រាប់គាំទ្រដល់ការសម្រេចបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល ដើម្បីបន្តរក្សាសន្តិភាព ស្ថិរភាព ក៏ដូចជាទ្រទ្រង់នូវដំណើរការវិវឌ្ឍឈានឡើងរបស់កម្ពុជា លើវិថីនៃការអភិវឌ្ឍ ប្រកបដោយគុណភាព និងចីរភាព តទៅមុខឥតឈប់ឈរ។**

ក្នុងន័យនេះ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយ ដែលបានលើកឡើងខាងលើ ជាពិសេសការបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់ នូវអភិក្រមការងារ ៥ យ៉ាង គឺ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** ។ ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ សូមមេត្តាផ្តល់ការគាំទ្រ និងចូលរួមអនុវត្តដោយសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះជោគវាសនារបស់ប្រទេសជាតិ និងឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់រាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ